Reçu le 30-3-50
INDOCHINE FRANÇAISE RÉGIE DU DÉPÔT LÉGAL

ព្រះរាជាណាចក្រ កម្ពុជា

មន្ទីរស្ដីការ ក្រសួងសិក្សាធិការ

# ទស្សនាវដ្ដី

សម្រាប់

គ្រូបង្រៀន

ឆ្នាំទី ១ លេខ ៧

ខែមីនា ព.ស. ២៤៩២

ឆ្នាំសិក្សា ១៩៤៩ - ១៩៥០

ព្រះរាជាណាចក្រកម្ពុជា

---

មន្ទីរស្ដីការ ក្រសួងសិក្សាធិការ

# ទស្សនាវដ្ដី
# សម្រាប់ គ្រូបង្រៀន

## បញ្ជីរឿង


| | ទំព័រ |
|---|---|
| ឧត្តមដ្ឋាន | ៣ |
| មជ្ឈិមដ្ឋានទី ២ | ៦ |
| — — ទី ១ | ៨ |
| វេយ្យាករណ៍ | ៩ |
| អាទិកដ្ឋាន | ១០ |
| បរិវច្ឆណដ្ឋាន | ១៨ |
| មេសូត្រវត់មាត់ | ២២ |
| លោកនីតិ | ២៧ |
| មជ្ឈិមដ្ឋានទី ២ តពុន្ត | ៣២ |
| — — ទី ១ | ៣៩ |
| រង្វាស់រង្វាល់ | ៤៣ |
| ធរណីមាណសស្រ្ដ | ៤៥ |
| អាទិកដ្ឋាន តពុន្ត | ៤៨ |
| រង្វាស់រង្វាល់ | ៥២ |
| បរិវច្ឆណដ្ឋាន តពុន្ត | ៥៤ |
| កុមារដ្ឋាន តពុន្ត | ៥៧ |
| អាទិកដ្ឋាន វត្ថុស្វាធ្យាយន៍ | ៦២ |
| បរិវច្ឆណដ្ឋាន វត្ថុស្វាធ្យាយន៍ | ៦៦ |
| បរិវច្ឆណដ្ឋាន វិធីបង្ការរោគ | ៦៨ |

ឧត្តមដ្ឋាន

# ពីឧឡារិកនៃបុណ្យបុះដៃ

បុណ្យនេះមានពេលធ្លាប់ពីថ្ងៃ ១៤ កើត ទៅថ្ងៃ ១ រោចខែកត្តិក ។ គឺជាបុណ្យបណ្តាច់ឆ្នាំបន្ទុគតិ មានរៀបពលីការដោយគ្រឿងសក្ការបូជា មានថ្វាយអម្បុក លយប្រទីប អុំទូក និងគ្រឿងសក្ការ ។

ឱកាសបុណ្យ ល់ហើយ ក្នុងទន្លេនៅមុខវាំងសឹងខានរៀបរៀបចំអុំទូកផង លើទឹកលើគោកការតុបតែងទូកពីធម្មតា ទាំងទូកងាក់ ទាំងទិស្សាន ។ ងាក់មកសំញើញបន្ទុមស្រួច នៅអែបនៃបទីងព្រះទីនាំងសុខក្សេម ។ ទូកនៃហៅនូវកញ្ចាលដំហើយនូវខ្លឹងដ័យពណ៌ព្រាល ខៀវ ស បក់រំបំ បតជិតយាមកេក្សព្រះដំណាក់ផែ ។ មានភេងក្រសាលសឹងពាសពាសទូវពណ៌នានា ។ នូវក្បាច់របនាក្បូរល្បស្បូកណើទឹងក្តឹងអត្តិសទី ។ ពេលប្រណាំងដល់ហើយ ទូកង ទូកមួងចេញត្រសងទៀបមុខព្រះពន្លា បីដូចនាគាត្រាប់កួងផលស័យ ។ សព្វស្បូប្រាប់គ្រឹប ។ អ្នកអុំគោះទូកជាសង្វាក់ មានអ្នករាំកាត់ក្បាច់កណ្តាលទេះឈេរទន្ទេងជាទីសំណើចនៃអ្នកមើល ។ ទូកអុំមួយទូកងលិអទឹងខុកម្រ័ក្សណ៍ខៀវស្រោល ក្បាលកន្ទេវ្រងើយខ្ពស់ បន្សំមិនហ្វាញ៉ាករំលេចរបនាស្អាផ្កាមាសក្រពិច ។ លូនលឿនរំលេចគួរសង្សារគយនទម៉ិនបង់វាក់ក្ដក ។ ទូកមួងច្រើនជាបែសតាម ពុំសូវមានក្បាច់ក្បូរទេ តែគួរសរសើរសង្វាក់ហ្វឹងដៃក្រៃវិស័យ ព្រោះពួកពាមសឹងធំពាញជាញជ័យខាងបែវទូក ។ មនុស្សមើលខឹលប្រលដូចទឹកហូរពុំអាចគិតគួរចំនួនឡើយ ។ តាមក្សែមាត់ច្រាំងស្ទឹង

ណៃទណាទ់តាទ់តាប់ផំមានពស្រោកណ៍ណាយលេចចំរុះពណ៌នានា ។ ភូនាជួប កំពលធំមួយពាសមាត់ទន្លេ ។ ឯអាកាសបរិក្យាយទ្រូតហើយដែលត្រាត់ បន្ទ្រី សត្វកញ្ញាស្មើស្រុកប្រិថពី ។ កត្រីក្ដួចថៃដោយប្រទេចផ្កាលាជំរោចនាដា វ្ស្សរុប ប្រាសាទក្ដីព្រោនព្រាតធ្ងះប្រះទាំងដលស័យ ទិង្សពួប្សជ្រូ ពិរោះល្វើយល្វិន បន្ទាភាចាំនវៃចន្ទ្រមទាំនខ្យល់ទុក្ខរបក់ផ្សព្វគាយជាទុកាស សប្បាយមួយនៃស្រុកយើង ។

---

ពាក្យពន្យល់.— នទ្យាវ័ក = លើសលុប ។ លយប្រទីប = ការណែកភ្លើងនៅទន្លេ ហ្ញ = សម្ពត់ពាមុខទូកង ។ ទូកមួង = ទូកងដែលគេចែវឲ្យលឿនទៅ ។ ដលស័យ = ទន្លេ ។ បន្ទាភា = (បន្ទ+អាភា) ពន្លឺព្រះចន្ទ្រ ·

ពាក្យសួរ.— អ្នកយល់ឃើញគួរបុណ្យនេះដូចម្ដេច ?— ដាន់ពីដើម គេធ្វើស្រះធំៗ ដូចបារាយណ៍,ស្រះស្រង់... នាអង្គរនោះតើប្រយោជន៍អ្វី? — ចូរប្រែពាក្យ សត្ថ,សប្ត,សត្វ,សត,សប្តិ។

# ស្ពានមុនីវង្ស (សារភាព)

នៅវេលាដែលបោយន្តចត់រង់ កុងតាមផ្លូវគោងគាត់ក្លួចប្បាររំពៅ សំដៅទៅទីក្រុងភ្នំពេញ បើអ្នកដំណើរងាកមើលទៅខាងលិចនឹងឃើញកែក់ទៅលើត្នូ ពងរបស់មួយសងខុន ដែលលេចចេញផុតពីចុងព្រៃកប្បាទាំងឡាយ ។ របស់នោះហាក់ឈ្នានែរកន៍ខ្ពស់ឡើងនៅវេលាដែលគេកាន់តែទៅជិត ។ អ្នកដំ-

ណើរដែលមិនសូវធ្លាប់ស្គាល់ទីក្រុង មិនសូវធ្លាប់ឃើញរបស់ចំឡែកថ្មីៗ កើតមានសេចក្ដីរំភើបក្នុងចិត្ត តៀតចូលទីគួរចំឡែកនោះ ជួនកាលលេចឡើងជាសណ្ឋានដំបូលស្រួចៗ ជួនកាលវែងរេតីរតើង ឧបមាដូចជាឆាកមួយធំសម្បើម ។ សេចក្ដីសង្ស័យលេតបាត់មួយរំពេច ដោយយល់ជាក់ថាជាស្ថានគឺស្ថានមុនីវង្សដែលកផកា បានសង់រួចមកជាងម្ភៃឆ្នាំហើយ ។ ស្ថាននេះវែងបណ្ដោយបីរយម៉ែត្រ សង់កាត់ជ្រុងខ្នងប៉ះល់តទទឹងទឹកហូរខ្លាញ់ក្បួចត្រ-បាញ់ក្នុងរដូវវស្សា ។ ស្ថាននេះបំពាក់ទ្រទ្រុងកណ្ដាល មានភាពជាស្ពានមួយធំក្រៃលែង ដែលយឹតកោងមកហើយដោយដៃព្រានព្រៃដ៏មានបុណ្យ ។ ដំបូលកណ្ដាលខ្ពស់លៃលែ ហាក់ទីងសង្កត់ស្ថានទាំងមូលឲណាក់ឲមូនទៅលើចុងសន្ទាងឲ្យត្រែងជាប់នៅ ។ របស់ទាំងអស់ដែលបកាត់ខ្វាត់ខ្វែងទាញទង់យឹត យ៉ាងខ្ជាប់ក្បៀងគ្នាទៅវិញទៅមក ។ បណ្ដោយស្ថានចែកជាបីសង្កាត់កណ្ដាលធំទូលាយសំរាប់ឲ្យយានជំនិះផ្សេងៗ បើកបរ សងខាងជាផ្លូវសំរាប់ឲ្យអ្នកថ្មើរជើងមានប្រកាន់ដៃជារបាំង ។ គេនឹកអស្ចារ្យទឹងទម្ងន់ផ្ទុកដែកធំៗដែលគាបលើកដាក់ផ្គាក់ផ្គុំគ្នាឡើង ជាស្ពានមួយយ៉ាងសម្បើម យ៉ាងល្អឯកនៅស្រុកខ្មែរ ។ គឺដោយហេតុតែស្ថាននេះហើយ ដំណើរទៅមកនៃអ្នកស្រុកខាងត្រើយភ្នំពេញនឹងអ្នកខាងត្រើយម្ខាងនៃទន្លេបាសាក់ ធ្វើបានដោយស្រួល ។ ស្ថាននេះជារបស់មានប្រយោជន៍យ៉ាងសំខាន់ ផលការដឹកនាំផលប្រយោជន៍ក្នុងស្រុក ចុះក្រៅស្រុកចូលទៅទីក្រុងភ្នំពេញ ។

**ពាក្យពន្យល់** ។ — សារភាព = ខ្លឹមសារនៃស្ពាន ។— សទទុង = សន្លស់វែង ។ រពើករពើង = ខ្នងធម្មស ស្ពានមិនស្មើ ពីខ្ពស់ទាប ខ្ពស់ទាប ។ — ផលប្រយោជន៍ = ទំនិញឬធនធាន កើតពីផែនដី ។

**ពាក្យសួរ** ។ — ព្រោះអ្វីគេដាក់ឈ្មោះស្ពាននេះឈ្មោះ មុនីវង្ស ? (ស្ដេចមុនីវង្សសម្ពោធស្ពាននេះក្នុងកាលដែលទើបទទួលរាជសម្បត្តិ) ។ — ស្ពាននេះកើតឡើងហើយ នោះតើផលប្រយោជន៍មានឡើងដូចម្ដេច ? ។ ព្យញ្ជនៈផ្សំឬផ្ញើជើង ត្រូវអានដូចម្ដេច ? ( ទុំសព្ទត្រូវក្រោមអានតាមតួលើ, ឯកសព្ទ អានទាំងលើទាំងក្រោមពេញមាត្រា ) ។

---

មជ្ឈមដ្ឋានទី ២

## អ្នកសូមទានតឹងគ្រាប់បែកបោះ

កាសែតទាំងឡាយនៃក្រុងបារីសតាំងពីម្សិលមិញ ពោលប្រកាន់ ទះថា ពួកកុម្មុយនិស្ត ទះថាពួកប្រឆាំងជាតិនិយម អំពីដំណើរផ្ទុះនៃគ្រាប់បែកដែលមានឡើងក្នុងសាលារៀននៅកណ្ដាលទីក្រុងបារីស ។ ម្សិលមិញក្រុមប៉ូលិសបានរកឃើញការពិត ថាហេតុគ្រោះនោះ មិនមែនជាបទនយោបាយឡើយ ។ អ្នកធ្វើឲ្យកើតហេតុនោះ គឺជាស្មូមយាចកចំណាស់ ៦០ ឆ្នាំ ដែលបានកាន់គ្រាប់បែកមួយមករើសជិតគំនរសំរាម ។ យាចកទៅឈប់សំណាក់ក្នុងសាលា បានបើកគន្លឹះគ្រាប់បែក ហើយប្រទះភ្លាមការគម្របដែលខ្ទេចខ្ទី ក៏ត្រូវផ្ទុះពេលគ្រាប់ទៅប៉ះគល់ឈើមួយ នៅគល់ឈើនោះមានក្មេងម្នាក់

ដែលស្លាប់ភ្លាមដោយត្រូវផ្ទុះ ។ យាបកខ្លួនឯងក៏ត្រូវរបួសដោយខ្យល់ផ្ទុះ ប៉ុន្តែគ្មានរបួសអ្វី ។ យាបកត្រូវគេចាប់ហើយគេចោទប្រកាន់ថាមានកំហុស ឥតប្រាប់ ។

---

១ ចូរផ្លាស់ប្រយោគខាងក្រោម បំពេញ ជាប្រយោគកម្ម (à la forme active)
២ ចូរអធិប្បាយន័យ "មាន" (ដែលមានឡើងក្នុងសាលារៀន)
៣ ន័យជាដូចម្តេច "បទ" (មិនមែនជាការនយោបាយ)
៤ អ្នកស្រុកបានបើកគន្លឹះត្រាប់បែកដោយមានគំនិតដូចម្តេច ?
៥ ការស្លាប់ក្មេងនោះតើញ៉ាំងឲ្យយាបកមានទោសសម្លាប់មនុស្សឬអ្វី ?

---

# ជម្បាញ

ត្បាញជាជំនាញការរបស់ស្ត្រី ។ ស្ត្រីជម្បាញអង្គុយលើគ្រែជាប់នឹងកីដៃប្រានទេញឈើ ជើងជាន់ឈ្នាន់ អំពោះអន្ទង់ក៏ឡើងម្ខាងៗទៀតចុះ កំពោះត្រល់ពីស្តាំទៅឆ្វេងកង់ចន្លោះអំពោះអន្ទង់ នោះអំពោះបាក់សា អ្នកជម្បាញទាញទេញឈើរត់អំពោះបាក់មកអំពោះលែ ពាក់មុន រួចជាន់ឈ្នាន់មួយទៀតពោះត្រល់ពីឆ្វេងទៅស្តាំ ហើយគោះទេញឈើរត់អំពោះបាក់តទៅទៀត ។ ជាងជម្បាញម្នាក់គេត្បាញ ១ ថ្ងៃ បានប្រាំបីម៉ែត្របណ្តោយសំពត់ដែលមានទេញឈើ សាមសិបប្រាំមួយសង់ទីម៉ែត្រ ។ សំពត់ជម្បាញមានច្រើនយ៉ាង មានក្រាស់ឬស្តើងតាមដោយគេត្រូវការធ្វើ ។

ពាក្យពន្យល់ ។ — កី = គ្រឿងសម្រាប់ត្បាញសម្ពត់ ។ — អំពោះអន្ទង = អំពោះសន្ទឹងបណ្ដោយកី; អំពោះចាក់ គឺអំពោះដែលខ្វែងប្រទាស់នឹងអន្ទង ។ — ធ្មេញឈើ = គឺធ្មេញធ្វើ ដោយឫស្សីឬដែក តាមប្រឡោះធ្មេញនោះគេដោតអំពោះអន្ទង ។ — ត្រល់ = បំពង់ឫស្សីពក ឬឈើ ក្នុងត្រល់នោះគេបញ្ចូលខ្នារអម្បោះសម្រាប់ពោះទាមកក្នុងអន្ទង ។ — ធ្មេញឈើសម្ពត់ ទទឹងសម្ពត់ ។

ពាក្យសួរ.— ចូររកពាក្យកិតៈ ឬក្រិត ដែលបែកចេញពីពាក្យ=ត្បាញ, ឈ្នាន់ ក្រាស់ ។

## មធ្យមដ្ឋានទី ១

# បងប្អូនពីរនាក់

*បងប្អូនពីរនាក់ទំហំស្មើគ្នា ឈ្មោះគាក លង់ ដោយគ្រាន់តែមានហេតុបន្តិចបន្តួច ។ ឪពុកប្រាប់ទាំងឡាយថា ចូរអ្នកស្ដាប់រឿងកំណាព្យមួយថា ថ្ងៃមួយដៃឆ្វេងប្រណាំងនឹងដៃស្ដាំ ក៏តាំងប្រវាយដណ្ដើមយកអ្វីដែលដៃស្ដាំកាន់ ។ ដៃទាំងពីរក៏ផ្ដល់នូវវាយគ្នាទៅវិញទៅមក ហើយបាននូវឈឺដៃខ្លួយដូចមួយ ។ នោះក្បាលនិយាយទៅកាន់ដៃទាំងពីរថា នែអ្នកឯងជាបងប្អូនបង្កើតសេ ដោយឈាមជាមួយគ្នាទេ ម្នាក់ធ្វើឲ្យម្នាក់ទៀតឈឺ គឺឈឺតែខ្លួនឯង ចូរអ្នកស្រុះស្រួលជួយគ្នាទៅវិញទៅមកវិញ ។ ឪពុកស្រដីថែមទៀតថា កូនអើយអ្នកឯងនេះប្រៀបដូចដៃនៃរឿងកំណាព្យត្រង់បទវាយគ្នានោះ ចូរកូនស្រឡាញ់គ្នាវិញ រួចក្រសោបកូនទាំងពីរក្នុងដៃ ហើយនាំឲ្យរាប់អានគ្នាទៅ ។*

---

ពាក្យសួរ.— ហេតុអ្វីគេទុកបងប្អូនដូចជាដៃទាំងពីរ ? — បងនឹងប្អូនដែលជានឹងគ្នា មានប្រយោជន៍ដូចម្ដេច ? — អក្សរសិថិលនឹងធនិត ប្រើការដូចម្ដេច ? — ពាក្យនៃបទនេះ មានពាក្យណាខ្លះដែលកើតពីសិថិលនឹងធនិត ។

# កូនរមិលគុណ

មនុស្សម្នាក់អង្គុយនៅមាត់ទ្វារផ្ទះជាមួយនឹងប្រពន្ធ ។ មនុស្សនោះហៀបនឹងបរិភោគមាន់ចៀនមួយ លុះឪពុកដើរមកដល់ ភ្លាមបុរសនោះលាក់មាន់ចៀនទៅក្រោមតុ ទិនកុំឲ្យឪពុកស៊ី ។ តាចាស់ផឹកទឹកមួយកែវហើយដើរហួសទៅ ។ លុះឪពុកទៅហួសហើយ កូនលូកដៃទៅក្រោមតុដើម្បីយកមាន់ចៀនស៊ីវិញ ក៏ប្រែទៅជាគីង្គក់ៗលោតមកទំលើមុខហើយនៅជាប់មិនទៅណាឡើយ ។ បុរសរមិលគុណនោះប្រឹងចិញ្ចឹមរក្សាគីង្គក់សព្វថ្ងៃ បើមិនធ្វើដូច្នោះ គីង្គក់នឹងត្របាក់ខាំមុខឲ្យលំបាកវេទនាខ្លាំង ។ តាំងពីនោះទៅរហូតដល់អស់ជីវិត មនុស្សនោះរងកម្មដូច្នេះ ។

---

១)– អំពើរបស់បុរសត្រង់ណាដែលគេថារមិលគុណ ហើយអំពើនោះឲ្យទុក្ខដូចម្ដេច ។

២)– គេស្គាល់ដូចម្ដេច ពាក្យដែលគេសរសេរ តម្រួតព្យាង្គដូចពាក្យអង្គុយ

៣)– ចូររកស័ព្ទពាក្យ = ទ្វារ, ទ្វា, ពន្ធ, ព័ន្ធ ប្រពន្ធ, ប្រព័ន្ធ

## វេយ្យាករណ៍

វិធីប្រើអាយតនិបាត វិធីប្រើអាយតនិបាតជាវិធីសំខាន់ក្នុងបទវេយ្យាករណ៍ គឺជាពាក្យប្រែវិភត្តិនោះឯង ប៉ុន្តែវិធីប្រើអាយតនិបាតជាបទពិស្ដារ (មើលមេរៀនដែលបានបង្រៀនហើយក្នុងទស្សនាវដ្ដីខែមេ ឆ្នាំ ១៩៤៨ ទំព័រពី ៣៦ ទៅទំព័រ ៨ ) ។

អានិកដ្ឋាន

## បង្រៀនពាក្យ-នឹងភាសា

### អានិត្យទី ១ – អំពីរុក្ខជាតិដែលមានសរសៃត្បាញបាន

នាម.– កប្បាស គរ ធ្មៃ ក្រចៅ ម្នាស់ ចេក ត្រកៀត ពោធិ៍ កៅស៊ូ ឬស្សី សំឡី សរសៃ ជ័រ សរសៃអន្ទង់ សរសៃបាក់ កីផ្លុះចោះកប្បាស សំលៀកបំពាក់ សំពត់អម្បោះ ។

គុណនាម.– ទន់ រឹង ស្វិត យឺត ដាច់ ផុយ មាំ ធ្មារ ប៉ោស រលីប រលីង គគ្រាត ។

កិរិយាសព្ទ.– កាត់ខោ-អាវ ដេរសំលៀកបំពាក់ ចោះកប្បាស ត្រាំក្រចៅ-ធ្មៃ រវៃអម្បោះ ចេចសំឡី ខារអម្បោះ អន្ទង់ ត្បាញ សកសំបក ។

ហាត់ភាសា.– សំលៀកបំពាក់ដែលយើងស្លៀកពាក់សព្វថ្ងៃបាន មកពីអ្វីខ្លះ? (បានមកអំពីឈើនិងសត្វ) អ្នកស្គាល់រុក្ខជាតិណាខ្លះដែលមាន សរសៃត្បាញបាន? នៅភូមិអ្នកគេដាំកប្បាសឬទេ? ឯកប្បាសគេដាំច្រើន នៅ ទីណា? នៅខែណា? ផ្លែកប្បាសទុំនៅខែណា? កាលណាផ្លែកប្បាសបែករកគេ ធ្វើដូចម្តេច? គេនាំកប្បាសទៅធ្វើដូចម្តេចទើបបានជាសំឡី? ខ្មែរយើងយក សំឡីកប្បាសទៅធ្វើអ្វី? (យកទៅធ្វើអម្បោះដូចត្បាញសំពត់កាត់ខោ-អាវ ធ្វើ ជាក្រមាខ្នើយពូក ធ្វើស្បៃមុង ។ល។) ។

ការហាត់សរសេរ .— ១— ចូរធ្វើឲ្យប្រកបនឹងពាក្យសួរខាងក្រោមនេះ — សំលៀកបំពាក់យើងសព្វថ្ងៃបានមកពីអ្វីខ្លះ? រុក្ខជាតិណាខ្លះដែលមានសរសៃត្បាញបាន? ។

២.— ចូររើសយក នាម គុណនាម កិរិយាសព្ទខ្លះមកដាក់ឲ្យសិស្សតែងធ្វើឃ្លាផងចុះ ។

## បង្រៀនមើល

### សិប្បិយការកើតពីសត្វ

សៀវភៅវត្ថុស្គាល់ព្យាយល់បឋមញ្ញាណដ្ឋានទំព័រ ១៥០ ។

ហាត់ភាសា .— សំពត់សូត្រយ៉ាងល្អគេធ្វើនឹងអ្វី? ដើម្បីនឹងស្រាវយកសរសៃសូត្រអ្នកស្រុកឆាយយកសំបុកសូត្រទៅធ្វើដូចម្ដេច? ហេតុអ្វីបានជាគេយកសំបុកសូត្រស្រុះក្នុងទឹកពុះហើយកូរនឹងចង្កឹះ? គេស្រាវសូត្រនឹងអ្វី? ស្រាវរួចហើយគេធ្វើដូចម្ដេចទៀត? ។ល។

## សរសេរតាមសូត្រ

### អំពីដើមកប្បាស

ដើមកប្បាសជារុក្ខជាតិតូចកំពស់មួយម៉ែត្រឬមួយម៉ែត្រកន្លះ គ្រាប់វាសម្បុរស ឬលឿងមានសំឡីរុំព័ទ្ធជុំវិញផ្លែបែកជារូតមានគ្រាប់នឹងកោមទន់ល្មើយនៅក្នុង

គឺរោមនោះហើយដែលហៅថាសំឡីកប្បាស  វាដុះនៅដីទួលហើយមានជីច្រើនផង  គេដាំកប្បាសនៅខែបុស្ស-មាឃ  ហើយគេបេះយកផ្លែ នៅខែជេស្ឋអាសាឍ ។ នៅស្រុកខ្មែរគេដាំកប្បាសនៅតាមទន្លេមេគង្គ ក្នុងខេត្តកំពង់ចាម ហើយនិងខេត្តកណ្ដាល ។ កប្បាសសំរាប់ត្បាញធ្វើសំពត់ហៅថាសំពត់អម្បោះ គេយកគ្រាប់ទៅស្ងោរប្រេងសំរាប់អុជ លាងម៉ាស៊ីន ហើយនិងធ្វើសាប៊ូ កាកសំរាប់ធ្វើជី ។

សរសេរពាក្យពីបាក .— កប្បាស រុក្ខជាតិ សប្បុរស រុំ ព័ទ្ធ ដុះ បុស្ស មាឃ ជេស្ឋ អាសាឍ កំពង់ កណ្ដាល ទន្លេ ប្រេង អុជ លាង ។

## តែងសេចក្ដី

### ចូរសរសេរឆ្លើយតាមពាក្យចោទសួរដូចខាងក្រោមនេះ

ពោតជាដំណាំគេដាំយកអ្វី? — ដើមវាមានកំពស់ប៉ុន្មានម៉ែត្រ? — ស្លឹកវាយ៉ាងដូចម្ដេច? — ផ្កាវាមានប៉ុន្មានយ៉ាង? — នៅដើមនិមួយៗ មានផ្កាប៉ុន្មាន? គ្រាប់ពោតមូលមានពណ៌ដូចម្ដេច? ពោតមានប្រយោជន៍ដូចម្ដេចខ្លះ? ។

## អក្សរផ្ចង់

ឃ ឈ យ ល ស ណ ឈឺឈ្នួល ឈប់ឈរ ឈាម បោលឈឹមឈ្លួសឈើ យាយសំយល់សម្ជ ។

# បង្រៀនពាក្យ-និងភាសា

## អាទិត្យទី ២- អំពីរោងកិនស្រូវ

នាម.— ស្រូវ ស្រូវខ្សាយ ស្រូវដំណើប អង្ករ អង្កាម ម្សៅ កន្ទក់ ត្បាល់ជាន់ (ត្បាល់កៀន) ត្បាល់កិន ត្បាល់បុក កញ្ច្រែង កញ្ជើ ល្អី ផារ រោងម៉ាស៊ីន (រោងយន្ត) ។

គុណនាម.— ធ្ងន់ ស្រាល រហ័ស យឺត ល្អិត ខ្ទេច ម៉ដ្ឋ ជ្រះ ជ្រាយ

កិរិយាសព្ទ.— កិនស្រូវ ជាន់-បុក (អង្ករ) បក់អង្កាម រែងកន្ទក់ ហាលស្រូវ រោយស្រូវ ។

ហាត់និយាយ.— គេធ្វើដូចម្តេចនឹងយកអង្កាមចេញពីស្រូវ? — ត្បាល់កិនខាងលើ (ខាងក្រោម) យ៉ាងដូចម្តេច? — គេធ្វើនឹងអ្វី? — ដើម្បីនឹងកិនស្រូវគេដាក់ដៃត្បាល់នៅឯណា? គេច្រកស្រូវនៅឯណា? ត្បាល់ខាងក្រោមភ្ជាប់នៅនឹងអ្វី? — លុះកិនស្រូវរួចហើយគេធ្វើដូចម្តេចទៀត? — ត្បាល់ជាន់វែងយ៉ាងដូចម្តេច? — អ្នកដែលជាន់អង្ករប្តូរទេ? — គេជាន់ប៉ុន្មានអង្រែទើបអង្ករស? ។ល។

ការហាត់សរសេរ — ចូរតែងជាឃ្លានឹងពាក្យមួយម៉ាត់ៗ ខាងក្រោមនេះ- ស្រូវ-អង្ករ-អង្កាម-កន្ទក់-ម្សៅ ឧទាហរណ៍ ពីម្សិលមិញខ្ញុំជួយកិនស្រូវបងប្រុសខ្ញុំអស់ចំនួនប្រាំថាំង ។

## បង្រៀនមើល

### រោងកិនស្រូវ

សៀវភៅដែលទំព័រ ១៣២ តាំងពីមុននឹងយកស្រូវមកប្រើការ ······ រហូតដល់ ······ ឯនៅស្រុកហាណូយនឹងហៃហ្វុង នឹងភ្នំពេញគេឃើញមានរោងកិនស្រូវដែរ ។

### ហាត់ភាសានិងហាត់សរសេរ.– *(សូមធ្វើដូចមុនៗ)* ។

## សរសេរតាមសូត្រ

### អំពីហាលស្រូវ

*ពីថ្ងៃអាទិត្យមុនមេឃស្រឡះ ព្រះអាទិត្យបញ្ចេញចំហាយខ្លាំងណាស់ ម្ដាយខ្ញុំបានប្រើបងខ្ញុំហើយនឹងខ្ញុំឲ្យហាលស្រូវ ដ្បិតជិតអស់អង្ករបរិភោគហើយ នោះបងខ្ញុំបាទហើយនឹងខ្ញុំបាទ ក៏យកកន្ទេលស្លឹកត្នោតមួយធំទៅក្រាលលើដីមួយកន្លែងកបស្ដើកទីធ្លា រួចបងខ្ញុំបាទហើយនឹងខ្ញុំបាទយកកញ្ជើមួយម្នាក់កៀបស្រូវពីជង្រុកប្រហែលជាបីថាំងយកទៅចាក់ដាក់លើកន្ទេលនោះ ហើយរាវស្រូវឲ្យមានកំពស់ស្មើគ្នាទាំងអស់ពេញកន្ទេល ខ្ញុំបាទនៅចាំមើលស្រូវកុំឲ្យមាន់ ទា មកស៊ី មកល្បារ ហើយខ្ញុំបាទរាស្រូវម្ដងៗផង ប្រយោជន៍ឲ្យស្ងួតសព្វទាំងអស់ ។*

### សរសេរពាក្យពីបាកឲ្យបំណាំ

*អាទិត្យ-មេឃ-បរិភោគ-បញ្ចេញ កប កញ្ជើ ជង្រុក រាវ សព្វ ។*

## តែងសេចក្តី

ចូរអ្នកអធិប្បាយអំពីការធ្វើអង្ករ តាំងពីហាលស្រូវកិនស្រូវ ដរាបដល់បាន អង្ករស (អង្ករសំរិទ្ធ) តើខ្មែរយើងធ្វើយ៉ាងដូចម្តេចខ្លះ? ការនេះជាការនឿយហត់ច្រើនឬទេ? អ្នកយល់ឃើញដូចម្តេច? ។

### ទំនងតែង

១ – សេចក្តីផ្តើម.— (នៅវេលាណាដែលហាលស្រូវ គេធ្វើដូចម្តេចខ្លះ) ។

២ – សេចក្តីរៀបរាប់ .— គេកិនស្រូវនឹងអ្វី? - កិនយ៉ាងដូចម្តេច? - គេជាន់អង្ករនឹងអ្វី? - គេអុំ - រែងឬបក់អង្ករនឹងអ្វី? - ពីព្រោះអ្វីបានជាគេអុំ? ។

៣ – យោបល់របស់អ្នក .— អ្នកយល់ឃើញដូចម្តេច?

(ការនេះនឿយហត់ច្រើនឬទេ គេធ្វើដូចម្តេចវិញទើបបានងាយផង) ។

## អក្សរផ្សង

ព ឭ ឮ ឈ ញ ឱ ពពៃញី ស្រុកពញាឭ ឮជកាលណោះ ចៅពញារក្សាភិបាល ។

## បង្រៀនពាក្យ-និងភាសា

### អាទិត្យទី ៣ .— អំពីថ្នាំ

**នាម** .— គ្រាប់ថ្នាំ ផ្លែថ្នាំ ស្លឹកថ្នាំ កូនថ្នាំ ថ្នាល រម្ងួរ សរសៃថ្នាំ ផ្ទិញ កាំបិតបែប ខ្សៀ បារី ។

**គុណនាម** .— ថ្នាំខ្លាំង ខ្សោយ មូល ស្តើង ក្រាស ឆ្ងារ ថ្លោស ស្ងួត សើម គ្រប់គ្រាន់ ក្រហមព្រឿង ស្វាយ ។

**កិរិយាសព្ទ** .— ព្រោះគ្រាប់ថ្នាំ ដាំកូនថ្នាំ បេះស្លឹកថ្នាំ បន្ទុំថ្នាំ ហាន់ថ្នាំ ហាលថ្នាំ យកសន្សើមថ្នាំ មូរបារី ញាត់ខ្សៀ ជក់បារី បុកថ្នាំ ។

**ពាក្យនិយាយ** .— ថ្នាំជាដំណាំគេដាំយកអ្វី? ដើម្បីនឹងដាំថ្នាំគេធ្វើដូចម្ដេច? ពេលណាដែលត្រូវដកកូនថ្នាំយកទៅដាំក្នុងចំការ? គេដាំចម្ងាយពីគ្នាប្រហែលប៉ុន្មានសង្ទីម៉ែត្រ? ដាំរួចហើយគេធ្វើដូចម្ដេចទៀត? កាលណាគេបេះស្លឹកថ្នាំ? គេយកស្លឹកថ្នាំទៅធ្វើដូចម្ដេចខ្លះ នឹងមូរជាបារីបាន? គេហាន់ថ្នាំនឹងអ្វី? ហាន់រួចហើយគេធ្វើដូចម្ដេចទៀត? ។ល។

## បង្រៀនមើល

សៀវភៅដដែលទំព័រ ១៣៩ តាំងពីគេបេះស្លឹកថ្នាំហើយគេយកមកក្រុំជារម្ងួរបន្ទុំទុកក្នុងម្លប់.... រហូតដល់.... គេដាំថ្នាំមិនបានចំនួនគ្រប់គ្រាន់អាស្រ័យទេ ។

## សរសេរតាមសូត្រ

### អំពីការធ្វើថ្នាំ

យកតាមសេចក្ដីដែលបានបង្រៀនមើលខាងលើនេះ តាំងពីគេដាំថ្នាំគ្រប់កន្លែងក្នុងប្រទេសឥណ្ឌូចិន ...រហូតដល់នៅស្រុកកូសាំងស៊ីននឹងស្រុកខ្មែរ គេដាំថ្នាំមិនគ្រប់គ្រាន់អាស្រ័យទេ ។

សរសេរពាក្យពិបាក — រុំ - កន្ទុំ - រមូរ - ហាន់ - ជ្រិញ - រុញ ឬស្សី - ថែប ។

## តែងសេចក្ដី

ចូរអ្នកអធិប្បាយអំពីការធ្វើថ្នាំ ដែលបានឃើញឬបានឮគេនិយាយ តើគេធ្វើដូចម្ដេចខ្លះ តាំងពីដាំដើមថ្នាំឡើងរហូតដល់បេះស្លឹកហាន់បានជាសរសៃ រួចហាលបត់បានជាបាញ់ថ្នាំស្រេច? - អ្នកយល់ឃើញថាគួរនឹងដាំថ្នាំច្រើនឬទេនៅស្រុកយើង? ។

### ទំនងតែង

១ សេចក្ដីផ្ដើម .– ( នៅភូមិអ្នកមានគេដាំថ្នាំឬទេ នៅវេលាណាដែលគេព្រោះគ្រាប់ថ្នាំគេធ្វើដូចម្ដេចខ្លះ? )

២ – សេចក្ដីរៀបរាប់ ·– គេដកកូនថ្នាំទៅដាំនៅចំការ ( គេធ្វើដូចម្ដេចខ្លះ? ការថែទាំកូនថ្នាំ ( គេធ្វើដូចម្ដេចខ្លះ? ) គេបេះស្លឹកថ្នាំយ៉ាងណា ហើយគេយកស្លឹកនេះទៅធ្វើដូចម្ដេច? ការហាន់ហើយនឹងហាលថ្នាំ ( គេធ្វើដូចម្ដេចខ្លះ)- គេយកសរសៃថ្នាំមកធ្វើដូចម្ដេចខ្លះ? ។

៣ – សេចក្ដីបញ្ចប់ ·– អ្នកយល់ឃើញដូចម្ដេចខ្លះ អំពីការធ្វើថ្នាំ ។

## អក្សរផ្ចង់

ព ឮ ឭ ឈ ញ ឪ គោពពាល ពន្លឺពិល ឭវណ្ណ

ព្រឹទ្ធាចារ្យ ព្រះព្រហ្មញញឹម ។

បរិច្ឆណាដ្ឋាន

## បង្រៀនពាក្យនិងភាសា

គ្រូកុំប្រើវិធីបង្រៀនពាក្យនិងបង្រៀនភាសា ដែលហៅថាបង្រៀនភាសានោះតែវិធីបន្ទំសិស្សហាត់និយាយ ឲ្យបានត្រឹមត្រូវ ឯបង្រៀនពាក្យគឺបង្រៀនសិស្សឲ្យស្គាល់ជាក់ឈ្មោះរបស់ផ្សេង ៗ ហើយកត់ឈ្មោះរបស់នោះឲ្យសិស្សចេះទន្ទេញផង ១ទៀតពាក្យដែលរៀនរួចនោះគួរឲ្យសិស្សចេះធ្វើជាឃ្លា ឧបមាដូចជាពាក្យ “ផ្ទុកម្ពាយ” ឲ្យថា “ផ្ទុកម្ពាយខ្ញុំនៅរីយលំបាកទីនិខ្ញុំណាស់” ។

## អាទិត្យទី ១.— អំពីក្រុមញាតិ

នាម.— វង្សត្រកូល, ពូជ, ញាតិ (ដំណមនុស្សត ៗ ដោយឈាមជាមួយ) សាខា (មែក) សាខាញាតិ, ញាតិសន្តាន (ញាតិពង្ស) ញាតិតន្ទ (ញាតិមិនតគ្នាដោយឈាមជាមួយ) ញាតិជិត, ញាតិឆ្ងាយ, ញាតិក្នុងស្រុក ។

គុណនាម.— ខ្ពស់, ទាប, ថោក, ថ្លៃ, មាន, ក្រ, រហេមរហាម, គោកយ៉ក, ដាច់ដាប, ទិលខ្លូប ។

កិរិយា.— ទំនុកបំរុង, ការពារ, គោរព, បន់គេ្ត រក្សាគេ្ត, ជៀលគ្នះ ។

បាត់ភាសា.— គេហៅថាអ្នកមមនុស្សដែលកើតត ៗ មក ៗ មនុស្ស

យ៉ាងដូចម្ដេចដែលសំដត្ថៈ ហៅមនុស្សឥតត្រកូល ៗ (មនុស្សខិលខូច) ដែលហៅមនុស្សមានត្រកូល ៗ (មនុស្សមានពូជខ្ពស់) ៗ ញាតិទាំងឡាយមានប៉ុន្មានជំពូក ៗ (ពីរជំពូក គឺញាតិជិតនិងញាតិឆ្ងាយឬសាខាញាតិ) ៗ ញាតិពន្ធនោះគឺជាញាតិយ៉ាងដូចម្ដេច ៗ (គឺជាញាតិខាងប្ដីនិងញាតិខាងប្រពន្ធ)

## អាទិត្យទី ២.— អំពីក្រុមញាតិ (ត)

នាម.— ឪពុក (បិតា), ម្ដាយ (មាតា), កូនប្រុស, កូនស្រី, បង, ប្អូន, អាយុ ៗ

គុណនាម.— ធំ, តូច, ក្មេង, ចាស់, លើ, ជំទង់, ច្រើន ៗ

កិរិយា.— បង្កើត, ចិញ្ចឹម, ថែទាំ, ស្រឡាញ់, គោរព ៗ

ភាសា.— ដូចម្ដេចដែលហៅថាក្រុមញាតិ ៗ ក្នុងក្រុមញាតិអ្នកមានអ្នកណាខ្លះ ៗ ឪពុកអ្នកឈ្មោះអ្វី? ម្ដាយអ្នកអាយុប៉ុន្មាន ៗ អ្នកមានបងប្អូនប្រុសប៉ុន្មាន ៗ ស្រីប៉ុន្មាន ៗ បងប្អូនស់អ្នកស្រីឬប្រុស ៗ គាត់ឈ្មោះអ្វី ៗ គាត់អាយុប៉ុន្មាន ៗ កូនប្រុសស្រីត្រូវធ្វើម្ដេចនឹងឪពុកម្ដាយ ៗ បងប្អូនប្រុសស្រីត្រូវធ្វើម្ដេចនឹងគ្នា ៗ ហេតុអ្វីបានជាអ្នកត្រូវគោរពឪពុកម្ដាយអ្នក ៗ

## អាទិត្យទី ៣.– អំពីក្រុមញាតិ (ត)

នាម.– ជីតា, ជីដូន, ឪពុកធំ, ម្ដាយធំ, មា, មីង, បងប្អូនជីដូនមួយ, បងប្អូនជីទួតមួយ, ចៅ, ក្មួយ, ក្មួយជីដូនមួយ ។

គុណនាម.– ចាស់, ជរា, អនិច្ចកម្ម, រស់, ស្លាប់, ញ័រ, (ដៃ) កោង (ខ្នង) ។

កិរិយា.– ឈ្លោះប្រកែក, គោរពប្រតិបត្តិ, ទំនុកបំរុង, ស្ដាប់បង្គាប់, ទូន្មាន, និយាយរឿង ។

ភាសា.– ជីតាអ្នកអាយុប៉ុន្មាន ។ ជីដូនអ្នកនៅរស់ឬអនិច្ចកម្មហើយ ។ គាត់ដើរទៅណាឆ្ងាយបានឬទេ ។ ពីព្រោះអ្វី ។ ជើងដៃគាត់ដូចម្ដេច ។ ឪពុកធំម្ដាយធំអ្នកនៅឯណា ។ គាត់រកស៊ីធ្វើអ្វី ។ គាត់មានកូនប្រុសស្រីប៉ុន្មាន ។ តាអ្នកត្រូវជាម្ដេចនឹងឪពុកអ្នក ។ ដូចម្ដេចដែលហៅថាបងប្អូនជីដូនមួយ ។ បងប្អូនជីទួតមួយអ្នកត្រូវជាម្ដេចនឹងមាមីងអ្នក ។ បើជីតាជីដូនឬមាមីងទូន្មានអ្វីៗ អ្នកត្រូវធ្វើដូចម្ដេច ។ ហេតុអ្វីបានជាត្រូវគោរពប្រតិបត្តិជីតាជីដូន ។ ដើម្បីឱ្យឪពុកម្ដាយសប្បាយចិត្តអ្នកត្រូវធ្វើដូចម្ដេច ។

## អាទិត្យទី ៤.– អំពីក្រុមញាតិ (ត)

នាម.–ឪពុកក្មេក, ម្ដាយក្មេក, បងថ្លៃ, ប្អូនថ្លៃ, កូនប្រសា, ក្មួយប្រសា ។

គុណនាម.— ខាប, ស្ងួត, ល្អ, ខាត្រក់, សុខសប្បាយ, ឈឺ ។

កិរិយា.— និយាយគួរសំ, និយាយលេង, រាប់អាន, ជួយគ្នា, ដោះទុក្ខគ្នា, ប្រកាន់ទោស, ធ្វើការច្រើន ។

ភាសា.— (សុំតែងពាក្យទោងសួរស័ស្រតាមរៀនផង)

## រៀនមើល-សរសេរ

អាទិត្យទី ១.— ក្រុមញាតិ.ឋា.កត

(សុំមើលក្នុងសៀវភៅវិជ្ជាខេមរភាសាថ្នាក់កុមារដ្ឋានទំព័រ ៩៥,៩៦)

អាទិត្យទី ២.— បងប្អូនបៅកេត

(សុំមើលក្នុងសៀវភៅវិជ្ជាខេមរភាសាថ្នាក់កុមារដ្ឋានទំព័រ ៩៧)

អាទិត្យទី ៣.— ស្រឡាញ់បងប្អូន

(សុំមើលក្នុងសៀវភៅវិជ្ជាខេមរភាសាថ្នាក់កុមារដ្ឋានទំព័រ ៩៨)

អាទិត្យទី ៤.— ត្រូវស្រឡាញ់កោតខ្លាចជីដូនជីតា

ជីដូនជីតាយើងគាត់នឿយព្រួយលំបាកនឹងចិញ្ចឹមឪពុកម្ដាយយើង ដូចជាមាតាបិតាយើងនឿយហត់នឹងរកចិញ្ចឹមយើងដែរ ហើយមួយទៀតជីដូនជីតាយើងគាត់ថែរទាំរក្សាយើងទៀតផង វេលាដែលឪពុកម្ដាយយើងមិននៅទៅធ្វើការ ហេតុនេះយើងត្រូវស្រឡាញ់ជីដូនជីតាយើង ដូចជាយើងស្នេហាមាតាបិតាយើងដែរ ។

មេសូត្រត់មាត់

សំរាប់គ្រប់ថ្នាក់

## ការរបាំ

ការរបាំទាំងឡាយច្រើន អាចនាំចំរើនប្រាជ្ញាពិត
ព្រមទាំងសតិវាងវៃគិត គំនិតឆ្លៀវឆ្លាតកើតស្មារតី ។
បម្លាក់ កំណាព្យ-នឹងគំនូរ ជំនាញក្បាច់ក្បូរជូរូបតន្ត្រី
របាំរាំលោតឬច្រៀងក្តី គប្បីយល់ថាការរបាំ ។

ពន្យល់ពាក្យ.— របាំ— ន. ការតាក់តែង; ការធ្វើឲ្យវិចិត្រផ្សេងៗ ។

សតិ— ន. គឺសេចក្តីនឹកឃើញ, ការរឭកបាន ។

វាងវៃ— គុ. ឈ្លាសវៃ, ប្រាជ្ញាវាងវៃ, គំនិតវាងវៃ ។

ឆ្លៀវឆ្លាត— គុ. ប៉ិន, ប្រសប់, ស្ទាត់ ។

---

## បម្លាក់

បម្លាក់ជាងឆ្លាក់នឹងដែកដាប់ សំរាប់ទម្លុះក្បាច់លេខា
វល្លិវ័ណ្ណព័ន្ធព័ន្ធទងភ្ញីផ្កា សំណាដៃជាងជំនាងល្អ ។
ដូចជាឆ្លាក់ក្បាច់នគរវត្ត ព័ន្ធព័ន្ធពេញផ្ទាំងជញ្ជាំងថ្ម
តាំងពីបូរាណច្រើនជំណា ក៏នៅបម្លាក់ក្បាច់ឆ្លាក់ស្អាត ។

ពន្យល់ពាក្យ.– បម្លាក់ – ន. រូបឬក្បាច់ដែលគេឆ្លាក់ (ការរចនា)

ដែកដាប់ – សមាសនាម ធ្វើឲ្យមុតដោយពន្លាកឬដោយរ៉ិត ។

លេខា – ន. ការគូរ, វាស, គំនូរ ។

ដំឆាង – ន. ចូឡៃ, ស្នាដៃរបស់ជាង ។

---

## គំនូរ

រូបគូរថ្លៃថ្នូរជាងរូបចិត ខូងផិតធំតូចដូចសុទ្ធសាធ
មួយវាសរៀបត្រង់ត្រឹមតាមខ្នាត មួយគូរសំអាតផាត់ពណ៌ស្រស់ ។
គំនូររេតគណិតសាស្ត្រ គូរផ្ទៃក្រដាសប្រើម៉ែត្រវាស់
រៀបត្រង់ជ្រុងមូលគ្មានទំនាស់ ឬខ្វាស់រូបផ្កាប់ហារបម្លង ។

ពន្យល់ពាក្យ.– រូបចិត – សមាសនាម រូបដែលថតតាមកញ្ចក់ថត ។

សុទ្ធសាធ – គុ. ដូចគ្នាជាប់ប្រិយ ។

រេតគណិតសាស្ត្រ – ន. ក្បួនបង្រៀនខាងបន្ទាត់, មុម, ផ្ទៃ, ទំរង់ ។ល។

---

## គំនូរ (ត)

គំនូរជាគ្រឿងលំអឯក នាំបែកគំនិតផើតបម្រុង
ឲ្យបេះគន់ខុសត្រង់ផង បំណងឲ្យឃើញទំនិតឆ្ងាយ ។

បើបេះគន្លងនោះមកមាំ អាចនាំកំសាន្តចិត្តសប្បាយ
រមែងឈ្វេងយល់ការទាំងឡាយ សាយដល់អាជីវប្រព្រឹត្តិ ។
អរិយប្រទេសផងនានា វិជ្ជាជាងគូរគំនូររឹត
តែថ្កើងរុងរឿងជាបណ្ឌិត វិចិត្តករដ៏ថ្លាថ្លៃ ។

ពន្យល់ពាក្យ.— ចម្បង— គុ. ដែលលើសគេ, ដែលជាច្បងគេទាំងអស់ ។

អាជីវប្រព្រឹត្តិ— សមាសនាម ដំណើរប្រព្រឹត្តិទៅនៃជីវិត ឬ មុខការរបរ សំរាប់ចិញ្ចឹមជីវិត ។

វិចិត្តករ— ជាងគំនូរ ន. ជាងគូរផាត់ព័ណ៌ ។

## ដូរ្យតន្ត្រី

ភ្លេងមានគ្រប់សាសន៍ក្នុងផែនដី ហៅដូរ្យតន្ត្រីគ្រប់សម័យ
ក្នុងលោកីយនេះនិយមក្រៃ ទុកជាដំឡៃថ្កើងរុងរឿង ។
ខាងឯភ្លេងខ្មែរទ្រខ្សែ៣ ចាប៉ីសាដៀវស្គរជាគ្រឿង
ដេញដំប្រគំច្រៀងតាមរឿង ខាងគ្រឿងភ្លេងសៀមរនាតគង ។

ពន្យល់ពាក្យ.— ដូរ្យតន្ត្រី— ន. គ្រឿងភ្លេងដេញដំផ្លុំកូត ។

លោកីយ—គុ. ដែលមានក្នុងលោក ។

និយម— ន. សេចក្តីកំណត់, ធម្មតា, ធម្មជាតិ ។

កិ, កំណត់, អនុលោមតាម ។

## របាំ

របាំបាក់ក្បាច់ក្រម៉ាប់កាយ    កែក្រាយទន្ទាំរាំឈៀងឈ្នង
តាមសព្ទពិណពាទ្យនាគគង    ឬតាមទំនងពោលបែងបា ។
ល្បែងកែរំខានបិត្តហ្មងសៅ    លោកហៅថាការរបា
មួយដែរធំកើងក្នុងរដ្ឋា    បណ្ដាជនមើលរាប់មិនអស់ ។

ពន្យល់ពាក្យ.– ពិណពាទ្យ– ន. គ្រឿងតន្ត្រីសម្រាប់ដំ វាយ ផ្លុំ ។
កែក្រាយ– កិ. ដើរយាងយាសទៅមកយ៉ាងដំណើរល្ខោនរាំ ។
បែងបា– កិ. ច្រៀង, សំដែង, ពោលពេញសម្លេងឮខ្លាំង, ពំនោលរឿងរាមកេរ្តិ៍ ។

## កំណាព្យ

ពាក្យកាព្យពាក្យឃ្លោងមានវគ្គឃ្លា    តែងជាប្អូនបងជាប់សម្ផស្ស
សមហេតុសមផលសេចក្ដីស្រស់    របស់នេះហៅការរបា ។
បណ្ឌិតបុរាណបានតែងបែប    ពិស្ដារសង្ខេបតាមសាស្ត្រ
កេរ្តិកាល-ច្បាប់ក្រមធម្មគ្រិត្យា    ឬសាស្ត្រល្បែងក៏តែងកាព្យ ។

ពន្យល់ពាក្យ.– សម្ផស្ស– ន. ខ្មែរហៅពាក្យចួនក្នុងកាព្យឃ្លោងដែលទទួលគ្នា ឬ ដែលមានសូរសព្ទធ្ងន់ស្រាលតាមកំណត់មាត្រាកាព្យថា:សម្ផស្សដែរ ។

## រឿងមើលកំសាន្ត

### ឆ្មានឹងកណ្ដុរចាស់ (តពីខែមុន)

ពេលមួយពិឡារ　　ក្លែងក្ស័យសង្ហារ
អាការរងកម្ម　　ជើងក្រោយខ្សែព្យួរ
បងព្យួរក្បាលដាំ　　ដួងចុះក្រោមចាំ
ប្រុងខាំសម្លាប់ ។
មុសិកសត្វ　　ឃើញហេតុវិបត្តិ
សត្រូវគេចាប់　　បងព្យួរនឹងខ្សែ
ភិយទាល់តែស្លាប់　　ទើបចេញខ្នាន់ខ្នាប់
ប្រាប់គ្នីគ្នាថា ។

ពន្យល់ពាក្យ.— ពិឡារ — គ. ឆ្មា ។
សង្ហារ — គ. សំពៀងកាយ ។
មុសិក —(ម.ថ. មុសិកៈ) គ. កណ្ដុរ ។
វិបត្តិ — គ. សេចក្ដីប្រែប្រួល ។

---

### ឆ្មានឹងកណ្ដុរចាស់ (ត)

កនបើងមើលនែ!　　អ្នកខ្លាំងពូកែ

ខ្សែព្យួរកាយា ជាក់ជាមិនរួច
ពីលួចភោគ្គា មច្ឆមំសា
ហារគេមិនលែង ។
ឬក៏ក្រញ៉ាំ ដៃជើងកូនចៅ
របស់គេឯង ទើបគេវាយស្លាប់
ចាប់ចងប្រតែង ប្រគោងខ្សែវែង
ជើងដៃជ្រែងទល់មេឃ ។

. . . . . . . . . . . . . . . . . . . . . . (នៅមានតទៅទៀត)

ពន្យល់ពាក្យ.– មច្ឆមំសាហារ– ន. (គឺមច្ឆៈ មំសៈ អាហារ) សាច់ត្រីជាអាហារ ។

## លោកនីតិ

### សម្រាប់គ្រប់ថ្នាក់

របៀបដែលត្រូវបង្រៀន លោកនីតិ ក្នុងខែមិនាដូចមានខាង
ក្រោមនេះ ។

បរិញ្ញាណផ្ទួន.– អំពីបុណ្យ- បុណ្យណាដែលសំខាន់ ប្រាកដជាងគេ- របៀបធ្វើបុណ្យ ។

អាទិកដ្ឋាន.— អំពីភូមិ-ពាក្យបណ្ដាំងផ្សេងៗ សំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍ មរណភាព ។

មជ្ឈិមដ្ឋានទី ១.— អំពីបុស្ដិ៍-របៀបរាជការ-នាយកបុស្ដិ៍-មុខក្រសួង ។

មជ្ឈិមដ្ឋានទី ២.— សេចក្ដីសមត្ថភាពនិង-ខ្មែរ- កិច្ចដែលត្រូវប្រតិបត្តិដល់ប្រទេសនិងមន្ត្រី អាណាព្យាបាល ។

ឧត្ដមដ្ឋាន.— ការពារប្រទេស-សេចក្ដីសន្តិសុខ-ក្រុមរក្សាប្រទេស. ក្រុមរក្សាព្រះអង្គ ។

បរិច្ឆេទដ្ឋាន

## អំពីបុណ្យ

ក្នុងកម្ពុជរដ្ឋយើងសព្វថ្ងៃនេះ មានរៀបពិធីធ្វើបុណ្យរាល់ខែ ឥតមានបន្លោះខែណាទេ ហៅថាបុណ្យទ្វាទសមាសឬពិធីទសមាស (ខែទាំងដប់ពីរ) ។ បុណ្យចូលឆ្នាំធ្វើតាមទំនៀមនៅខែចេត្រ ខែពិសាខប្រត់ព្រះន័ង្គ័ល ខែអាសាឍចូលវស្សា ។ បុណ្យតាំងតុគឺពិធីបំរើនព្រះជន្មធ្វើនៅថ្ងៃខែ ដែលព្រះមហាក្សត្រីយប្រសូត ខែភទ្របទធ្វើបុណ្យភ្ជុំបិណ្ឌ ខែអស្សុជចេញវស្សា ខែកត្ដិក អុំទូកសំពះព្រះខែ ។ បុណ្យកឋិនធ្វើខែហាប់តាំងពីថ្ងៃ១រោចខែអស្សុជ ។ ខែផល្គុណបញ្ចាន់ត្រិស្ដ ។ ក្រៅពីនេះមានបុណ្យផ្សេង ៗ ទៅទៀត ប៉ុន្តែពុំបានជាឧឡារិកទេ ។

ពាក្យសួរ. — នៅប្រទេសយើងមានរៀបពិធីធ្វើបុណ្យដូចម្ដេចខ្លះ · យ៉ាងដូចម្ដេចដែលហៅថាបុណ្យភ្ជាទសមាស ។ បុណ្យណាខ្លះដែលអ្នកស្គាល់ ។ បុណ្យចូលឆ្នាំគេធ្វើនៅខែណា ។ល។

អាទិតដ្ឋាន

អំពីភូមិ - ពាក្យបណ្ដឹងផ្សេង ៗ សំបុត្រកំណើត - សំបុត្រអាពាហ៍ពិពាហ៍ - សំបុត្រមរណភាព ។

សុំមើលទស្សនាវដ្ដី លេខ ១ និង ៤ គ.ស. ១៩៤៩ មានរបៀបបង្រៀនសព្វគ្រប់ហើយ ។

មជ្ឈិមដ្ឋាន ទី ១

អំពីបុស្ដ

បុស្ដិ៍គឺជាចំណែកមន្ទីរធ្វើការមួយ ខាងរាជការរដ្ឋបាល នៅក្នុងឧភិទ ចៅហ្វាយស្រុក ។ ទីបុស្ដិ៍មួយ ៗ ពីដើមច្រើនតែកន្លែងស្រុកចាស់ ដល់គេរួមស្រុកពីរជាស្រុកមួយទៅ នោះទីស្រុកចាស់បង្កើតទៅជាបុស្ដិ៍វិញ ជួនកាលគេតាំងបង្កើតបុស្ដិ៍ក៏មានដែរ នៅដំបន់ណាដែលមានឃុំជិត ៗ គ្នា ហើយឃុំទាំងនោះនៅឆ្ងាយពីសាលាស្រុកផង ដើម្បីឲ្យមេឃុំងាយទៅមកកាន់បុស្ដិ៍តាមផ្លូវរាជការ មិនចាំបាច់ទៅសាលាស្រុកដែលនៅឆ្ងាយ ។

នៅបុស្តនីមួយៗមាននាយកបុស្ត (សែរ៉ុហ្វបុស្ត) មានស្មៀន និងប៉ូលិសឃុំ ធ្វើការដូចជាសាលាស្រុកដែរ ដើម្បីការពាររាស្ត្រឲ្យបានសន្តិសុខ ទទួលប្រាក់ពន្ធគ្រប់ជំពូកពីមេឃុំ ហើយនឹងពាក្យបណ្តឹងផ្សេងៗរួចបញ្ជូនទៅសាលាស្រុកតាមក្រសួង ។

ពាក្យសួរ.– យ៉ាងដូចម្តេចដែលហៅថាបុស្ត ។ ពីព្រោះអ្វីបានជាគេបង្កើតឲ្យមាននៅក្នុងស្រុកនីមួយៗ ។ បើមានចៅហ្វាយស្រុកត្រួតត្រាទីនោះហៅថាបុស្តបានឬទេ ហៅថាអ្វីវិញ ។ គេជ្រើសតាំងមន្ត្រីបែបណាឲ្យធ្វើជាសែរ៉ហ្វបុស្ត (យោក្ប័ត្រឬស្មៀនថ្នាក់ខ្ពស់) ។ល។

### មជ្ឈដ្ឋាន ទី ២

## សេចក្តីសាមគ្គី បារាំង-ខ្មែរ

កម្ពុជរដ្ឋពីដើមនៅក្នុងទំនុកបំរុងនៃនគរបារាំងសែស ឥឡូវនេះប្រទេសយើងបានឋានៈជាឯករាជ្យក្នុងសហភាពបារាំង ដូចមានសន្ធិសញ្ញាចុះថ្ងៃ ៨ វិច្ឆិកា គ.ស. ១៩៤៩ ស្រាប់ ។ ការចំរើនទាំងនេះមកពីសេចក្តីសាមគ្គីបារាំងខ្មែរ ដែលខំធ្វើការរួបរួមគ្នាដោយស្មោះត្រង់ជាយូរឆ្នាំណាស់មកហើយ ដើម្បីការពារប្រទេសឲ្យបានសុខក្សេមក្សាន្ត ហើយឲ្យបានបរិបូណ៌នូវភោគសម្ប័ទទៀតផង ។

ហេតុនេះជនជាតិខ្មែរត្រូវធ្វើការ កាន់ចិត្តស្មោះត្រង់កុំប្រទុស្ត-រាយ ឲ្យបែកបាក់សាមគ្គីនឹងគ្នា ជួយជ្រោមជ្រែងលើកស្ទួយកម្ពុជរដ្ឋ ដែលកំពុងកសាងឯករាជ្យ ឲ្យបានទៅជារដ្ឋមួយទាន់សម័យ សម នឹងអារ្យធម៌របស់ជាតិយើង ។

ពាក្យសួរ.— ប្រទេសយើងពីដើមនៅក្នុងចំណុះប្រទេសណា ។ ពីព្រោះអ្វីបានជាប្រទេសយើងសុំឲ្យប្រទេសបារាំងមកជួយការពារ ។ ឥឡូវកម្ពុជរដ្ឋបានឈ្នះយ៉ាងដូចម្ដេច ។ ពីព្រោះអ្វី ។ ជនជាតិខ្មែរត្រូវធ្វើយ៉ាងណា ដើម្បីឲ្យប្រទេសកម្ពុជាបានឯករាជ្យទាន់សម័យ ។ល។

ឧត្តមដ្ឋាន

## សេចក្ដីសន្តិសុខ

សេចក្ដីសន្តិសុខកើតឡើងពីសេចក្ដីស្ងប់ ប្រទេសណាដែលបាន សាន្តត្រាណ ប្រទេសនោះនឹងបានចំរើនហើយនឹងបានថ្កើងរុងរឿងពិតប្រាកដ ។ ប្រទេសកម្ពុជាយើងបើនឹងបានសន្តិភាពដូចអតីតកាលឡើងវិញ លុះណាតែជនជាតិខ្មែរ ប្រែគំនិតបេះរួបរួមពួកដៃគ្នា តាំងចិត្តស្មោះត្រង់នឹងមាតុភូមិ កុំប្រទុស្តរាយនឹងគ្នាឲ្យសោះ ។ ពិតមែនតែប្រទេសយើងមានក្រុមទាហានរក្សាប្រទេស ក្រុមរក្សាព្រះអង្គ ក្រុមឯកទេស នឹងរាជការក្រុមមឿងការពារនគរនឹងសេចក្ដី

អសន្តិសុខ ក៏ឃើញថាពុំបានគ្រប់គ្រាន់ដែរ ដូចសព្វថ្ងៃនេះបើប្រដូចទៅប្រទេសគេជិតខាង ហើយខេមរជនខ្លះនៅបែកសាមគ្គីនឹងគ្នាពុំទាន់បានស្រុះស្រួល បួលមករួបរួមកម្លាំងជាមួយគ្នាទៀតផង ការណ៍នេះហើយដែលបង្កើតឲ្យមានអសន្តិសុខ ។

ពាក្យសួរ.— ប្រទេសយើងសព្វថ្ងៃមានសេចក្ដីសន្តិសុខឬទេ ។ ពីព្រោះអ្វី ។ នគរណាដែលបានចំរើនមកពីអ្វី ។ ត្រូវធ្វើដូចម្ដេចនឹងបានប្រទេសសាន្តត្រាណ ។ ប្រទេសយើងមានគ្រឿងប្រដាប់ការពារសត្រូវគ្រប់គ្រាន់ឬទេ ។ ពីព្រោះអ្វី ។ល។

មេរៀនគ្រប់ថ្នាក់ខាងលើនេះគឺជាគំរូទេ បើពុំបានគ្រប់គ្រាន់ សុំតែងតាមត្រូវការឲ្យបានបរិបូណ៌ផងចុះ ។

មជ្ឈមដ្ឋានទី ២

## នព្វន្ត

## អាទិត្យទី ១.– លេខបែកដែលមានជើងហារលើសពី ២ ខ្ទង់ឡើងទៅ

### ១ – ចំនួនជើងល័ព្ធមានតែលេខ ១ ខ្ទង់ ។

ឧបមាថា = ប្រាក់ ១៩២៧ រៀល ចែកឲ្យមនុស្ស ៣៨៩ នាក់ តើម្នាក់ៗបានប៉ុន្មាន ។ នឹងរកល័ព្ធឲ្យងាយឆាប់ឃើញ តើមានលេខប៉ុន្មានខ្ទង់នោះត្រូវយកជើងហារគុណនឹង ១០ ។ បើឃើញច្រើនជាងចំនួនដំណាំង នោះជើងល័ព្ធប្រាកដមានតែលេខមួយតួទេ ។ ១៩២៧ : ៣៨៩ = ......... ៣៨៩ ដប់ដង ៣៨៩០ ឃើញថាលើសពីចំនួនដំណាំង ដូច្នេះនៅល័ព្ធត្រូវមានតែលេខ ១ តួ ។

| | | |
|---|---|---|
| ១៩៤២៧ \| ៣៨៩ | ១៩៤២៧ \| ៣៨៩ | ១៩៤២៧ \| ៣៨៩ |
| ៨២ \| ៥ | ៧៦០ \| ៣ | ៣៧១ \| ៤ |
| លេខល័ព្ធធំពេក លើសលេខដំណាំង | លេខល័ព្ធតូចពេក សល់ ៧៦០ ច្រើនជាង ផើងហារ | លេខល័ព្ធល្មមសល់ ៣៧១ តិចជាងផើងហារ |

## ២– ចំនួនផើងល័ព្ធមានលេខច្រើនខ្ទង់ ។

ឧបមាថា : ប្រាក់ ២៨៩.៥៨២ រៀល ចែកគ្នា ៦៣២ នាក់ ។

| | |
|---|---|
| ២៨៩៥៨២ | ៦៣២ |
| ៣៦៧៨ | ៤៥៨ |
| ៥១៨២ | |
| ១២៦ | |

នឹងចែកលេខដែលផើងហារនឹងល័ព្ធមានច្រើនខ្ទង់ នោះ គេត្រូវចែកដូចជាលេខដែលមានផើងហារ ២ ខ្ទង់ដែរ ។

សូមមើលរបៀបចែក ដែលបានចុះក្នុងទស្សនាវដ្ដីខែមុន នេះចុះ ។

## ៣– ការហាត់ធ្វើលេខ ។ ចូរធ្វើលេខខាងក្រោមនេះ ។

៣៧.៩៤៨ : ៧២៦១ = ............ ៤៦.០៨១ : ៦៥៨៣ = ........

១៩.៤១៦ : ៣២៥២ = ...... ...... ៣៤.៥០៩ : ៤៩៨២ = ........

ក្នុង ៥៧.៨៣២ ម៉ែត្រមាន ៤៨ ម៉ែត្រ ប៉ុន្មានដង ?

ក្នុង ៨៣២.០៤៨ លីត្រមាន ២៤៥ លីត្រ ប៉ុន្មានដង ?

## ៤– បំណោទ ។ ជង្គៅម្នាក់មានប្រាក់ ៥០.៦៩២ រៀល បើកឲ្យកូនឈ្នួល ២៩ នាក់ តើម្នាក់ៗ ត្រូវបានប៉ុន្មានរៀល ។

នឹងតខ្សែទូរសព្ទចម្ងាយ ១២១ គ.ម. ៨០០ តើត្រូវប្រើខ្សែលួសស្ពាន់ប៉ុន្មានចង្វាយ បើមួយចង្វាយប្រវែង ៧៥ ម៉ែត្រ ?

មនុស្ស ១២ នាក់ត្រូវបានរង្វាន់ទាំងអស់១៨៤០រៀល ។ ក្នុងមនុស្ស១២នាក់នេះមានមនុស្សខ្លះខានតខានបានរង្វាន់ ខ្លះទៀតបានម្នាក់ៗ ២៣០ រៀល តើមនុស្សដែលខានមិនបានរង្វាន់ប៉ុន្មាននាក់?

រទេះមួយផ្ទុកបានអង្ករ ៤៨២ ដុំ តើត្រូវការរទេះប៉ុន្មានទឹងដឹកឲ្យអស់អង្ករ ៣០០០ ដុំ ។

## អាទិត្យទី ២.— លេខគុណចំនួនបែងភាគគត់

១– ចំនួនដំណាំងជាចំនួនបែងភាគគត់ គុណនឹងចំនួនគុំ

**ឧទាហរណ៍**= លួស ១ បង្កាយ ប្រវែង ៥៣ ម៉ែ,២៦ តើលួស ១៣ បង្កាយមានប្រវែងប៉ុន្មានម៉ែត្រ ។

| | |
|---|---|
| × ៥៣,២៦ | ដើម្បីនឹងគុណលេខ ៥៣ម៉ែ.២៦ នឹង ១៣ នោះ គេសរសេរចំនួន |
| ១៣ | ទាំង ២ នោះមួយពីលើមួយពីក្រោម ហើយគេគុណដូចជាចំនួនគុំ |
| ១៥ ៩៧៨ | ធម្មតាដែរ ឥតមានអារម្មណ៍នឹងគណ្ឌកសញ្ញាឡើយ ។ |
| ៥៣ ២៦ | ឃើញបានដើងល័ព្ធ ៦៩.២៣៨ ម៉ែ. ឬ៦៩២ ម៉ែ ៣៨ ដូចមាន |
| ៦៩ ២៣៨ | គំរូជាប់មកនេះ ។ |

លុះគុណបានល័ព្ធ ៦៩២៣៨ ហើយគេត្រូវដាក់កណ្ឌកសញ្ញានៅខាងស្តាំល័ព្ធតាមចំនួនខ្ទង់លេខបែងភាគ ដែលមាននៅក្នុងចំនួនដំណាំង ។ យើងដឹងថាក្នុងចំនួនដំណាំងមានលេខបែងភាគគត់ ២ ខ្ទង់ ដូច្នេះ ៥៣.២៦ × ១៣ = ៦៩២ ម៉ែ, ៣៨ ។

## ២– ចំនួនដំណាំងនឹងមេគុណចំនួនបែងភាគដូចគ្នា

| |
|---:|
| ៣៧៥,៤ |
| × ២,៣៦ |
| ២២៥២៤ |
| ១១៣៦២ |
| ៧៥០៨ |
| ៨៨៦,៩៤៤ |

ឧបមាថា= បើគេចង់គុណលេខ ៣៧៥,៤ នឹង ២,៣៦ នោះ គេត្រូវធ្វើលេខដូចបានអធិប្បាយខាងលើនេះដែរ តែដល់ឃើញលទ្ធប៉ុន្មានៗ ហើយត្រូវកុំភ្លេចដាក់កណ្ដក់សញ្ញា ចំណុចនៅខាងឆ្វេងលទ្ធ តាមចំនួនលេខបែងភាគ ដែលមានក្នុងចំនួនដំណាំងនឹងក្នុងចំនួនមេគុណ ។

បើជាចំនួនដំណាំងឬចំនួនណា ១ ជាលេខបែងភាគគត់ ហើយចំនួន ១ ទៀតមានសូន្យនៅខាងចុង នោះគេត្រូវធ្វើលេខឥតបារម្ភនឹងសូន្យ ហើយនឹងកណ្ដក់សញ្ញាឡើយ រួចគេថែមសូន្យជាមុន ទើបដាក់កណ្ដក់សញ្ញាជាក្រោយ ដូចមានខាងក្រោមនេះ ។

| | |
|---:|---:|
| ២៥៦០០ | ៤,៥០៧ |
| × ៣,៤ | × ២០៨០ |
| ១០២ ៤ | ៣៦០៥៦ |
| ៧៦៨ | ៩០១៤ |
| ៨៧០ ៤០,០ | ៩៣៧៤,៥៦០ |

## ៣– ការហាត់ធ្វើលេខ= ចូរធ្វើលេខខាងក្រោមនេះ ។

៨.៥៤២ × ២៦,៣៥ = ......... ៤៩០៦ × ៦០,៨៤ = ............

៧៩៤៨ × ០,៨៥៧ = ........... ៤៨៤,៧ × ៩៨៦ = ..............

៦៨៧,៤ × ៩,៨៥ = ........... ៤៧៩០០ × ៨៧,៦ = ............

## ៤– បំណោទ ។ កំណាត់សំពត់ ១ ម៉ែត្រថ្លៃ ១២ʳ,៣៥ សំពត់ជនេះ

១៣ម,៦៥ ថ្លៃប៉ុន្មាន ។

នៅក្នុងរោងផាង ១ មានជាង ២៣ នាក់ ម្នាក់ៗបានឈ្នួល ១៥'៥៥ ។ ជាងទាំងអស់ធ្វើការ ៣១២ ថ្ងៃក្នុងមួយឆ្នាំ តើប្រាក់ឈ្នួលសរុបទាំងអស់ប៉ុន្មានរៀលក្នុង ១ ឆ្នាំ ។

ស្រូវមួយលីត្រ មាន ២៣.០០០ គ្រាប់ តើដប ១ ចំណុះ ០លី,៦៥ ដាក់ស្រូវបានប៉ុន្មានគ្រាប់ ។

ស្រា ១ លីត្រទម្ងន់ ០គក្រ,៨៦០ តើស្រា ១ ដបចំណុះ ០លី,៨៥ ទម្ងន់ប៉ុន្មាន ។

## អាទិ៍រៀនទី ៣ – អំពីចំនួនអនិយមភាគ

### ១– លេខសងដែលមានចំនួនអនិយមភាគ ។

ឧទាហរណ៍ ភ្លៀងចាប់ពីម៉ោង ៨ និង ៤២ មីនុត ៣៨ នាទី ទៅដល់ម៉ោង ១១ និង ១៧ មីនុត ២២ នាទី តើភ្លៀងនេះអស់ពេលប៉ុន្មានម៉ោង ?

សំរំលឹកថា = លេខហូត ដែលមានចំនួនជាអនិយមភាគបែបនេះមិនមែនធ្វើដូចជាលេខសងធម្មតាទេ ត្រូវហូតម៉ោងដោយម៉ោង មីនុតដោយមីនុត នាទីដោយនាទី ដូចខាងក្រោមនេះ ។

   ១១ម ១៧មន ២២ន
– ៨ម ៤២មន ៣៨ន
―――――――――

គេត្រូវធ្វើលេខចាប់ពីស្តាំទៅឆ្វេងដូចលេខសងធម្មតាដែរ តែលេខខាងលើ ២២ នាទី តូចជាង ៣៨ នាទី ដូច្នេះត្រូវថែម ៦០ នាទីទៅលើ ២២ នាទី ទើបហូតបាន ហើយត្រូវថែម ១មីនុតទៅខ្ទង់មីនុតខាងក្រោម ដើម្បីឲ្យចំនួននៅស្មើគ្នាដដែល មិនប្រែប្រួលបានជា ៤៣ មីនុត ។ ១៧ មីនុតតូចជាង ៤៣ មីនុតកំហូតពុំកើតទៀត ត្រូវថែម ៦០ មីនុតទៅលើ ១៧ មីនុត ហើយថែម ១ម៉ោងទៅលើខ្ទង់ម៉ោងខាងក្រោមទៀត ដូចតំរូវខាងក្រោមនេះ ។

| | | |
|---|---|---|
| ១០ ម | ៧៦ មន. | ៨២ ន. |
| − ៨ | ៤២ | ៣៨ |
| ២ ម | ៣៤ មន. | ៤៤ ន. |

២– ការហាត់ធ្វើលេខ ។ ចូរធ្វើលេខខាងក្រោមនេះ ។

១៤ ម ១៣ មន ៥៤ ន – ២៦ មន ៤៧ ន = .....................

១១ ម ១៤ មន – ៧ ម ២៦ មន ៣១ ន = .....................

៧ ម ៥ ន – ២ ម ១៣ មន ៨ ន = ..................... ..... .....

៣– បំណោទ រត់ភ្លើងមួយខ្សែចេញពីភ្នំពេញ ពីម៉ោង៧នឹង៣១ មីនុត ៤៥នាទី ទៅដល់បាត់ដំបងម៉ោង ១៦ នឹង ៥៣ មីនុត ២៧នាទី តើរត់ភ្លើងនេះបើកពីភ្នំពេញទៅប៉ុន្មានម៉ោងទើបដល់បាត់ដំបង ។

រថយន្តដឹកទំនិញមួយចេញពីពោធិ៍សាត់ពីម៉ោង៩ នឹង ៤១ មីនុត តើរថយន្តនេះបើកប៉ុន្មានម៉ោង បើវាមកដល់ភ្នំពេញម៉ោង១២ នឹង៦មីនុត ។

សូមលោកគ្រូជ្រើសរើសរកបំណោទផ្សេងៗ ដាក់ឲ្យសិស្សធ្វើទៀតផងចុះ ។

<u>អាទិត្យទី ៤</u> សូមលោកគ្រូបង្រៀនលេខបែក ដែលមានជើងហារច្រើនខ្ទង់ ៗ មានល័ក្ខ ១ ខ្ទង់ ៗ ល័ក្ខច្រើនខ្ទង់ ៗ លេខគុណមានចំនួនបែងភាគគត់ នឹងលេខសងមានចំនួនជាអនិយមភាគសារឡើងវិញ ៗ

## ការហាត់គិតរកនឹងប្រាជ្ញា

១– គុណលេខនឹង១០នឹង១០០នឹង១០០០ ៗ ក– ដើម្បីគុណចំនួនដុំនឹង ១០ នឹង ១០០ នឹង ១០០០ គេត្រូវថែមសូន្យ ១ សូន្យ២ សូន្យ៣ ទៅខាងស្ដាំចំនួនដុំ ៗ

២៧ × ១០០០ = ២៧០០០ ៗ   ៥៦៨ × ១០ = ៥៦៨០ ៗ

៤០៨ × ១០០ = ៤០៨០០ ៗ   ១៥ × ១០,០០០ = ១៥០០០០ ៗ

ខ– ដើម្បីគុណចំនួនបែងភាគគត់នឹង ១០ នឹង ១០០ នឹង ១០០០ គេត្រូវរុំកិលបង្ខិតកណ្ដក់សញ្ញា ១ខ្ទង់ ២ខ្ទង់ឬ៣ ខ្ទង់ទៅខាងស្ដាំចំនួនបែងភាគនោះ ៗ

៣៥,១៣ × ១០ = ៣៥១,៣ ៗ   ០,០០៥៧ × ១០០០ = ៥,៧

៣៥ ១៣ × ១០០ = ៣៥១៣ ៗ   ០,០០៥៧ × ១០០០០ = ៥,៧

២– ដើម្បីបែកចំនុនដុំនឹង១០នឹង ១០០នឹង១០០០ នោះគេត្រូវដាក់កណ្ដក់សញ្ញាថែម ១ខ្ទង់ ២ខ្ទង់ ៣ខ្ទង់ ដូចខាងក្រោមនេះៗ

៤៥៨:១០=៤៥,៨ ។ ៦៧០០:១០=៦៧០

៤៥៨:១០០០=០,៤៥៨ ។ ៧៩០:១០០=៧,៩០

បើចែកបំនួនចែងភាគគត់នឹង ១០ នឹង ១០០ នឹង ១០០០ នោះរំកិលបង្គិតកណ្ដក់សញ្ញា ១ ខ្ទង់ ២ ខ្ទង់ ៣ ខ្ទង់ ទៅខាងឆ្វេង

៦២,៤:១០=៦,២៤ ។ ៤,៧:១០=០,៤៧ ។

៦២,៤ ១០០=០.៦២៤ ។ ៤០៦,៣២:១០០០=០,៤០៦៣២ ។

បំណោទ ។ អ្នកជំនួញម្នាក់បានទិញសៀវភៅក្បួននព្វន្ត ១.០០០ ក្បាលថ្លៃ ៦៥០០រៀល ។ អ្នកជំនួញនោះលក់សៀវភៅទាំងអស់ទៅវិញបានបំណេញ ២៥០០ រៀល តើសៀវភៅ១ក្បាលលក់ថ្លៃប៉ុន្មានរៀល ។

មជ្ឈមដ្ឋានទី ១

នព្វន្ត

## អាទិត្យទី ១ ១ អំពីលេខគុណបំនួនទសភាគ

ក) លេខតាំងជាបំនួនទសភាគ

ឧបមា — បោកមួយស្លឹកថ្លៃ ២រ,៣៧ តើបោក ៣ ស្លឹកថ្លៃប៉ុន្មាន ។

របៀបពន្យល់ រូបិយវត្ថុឲ្យសិស្សរាប់ – ចូរឯងរាប់រូបិយវត្ថុឲ្យត្រូវនឹងថ្លៃបោក ១ ស្ទិត (២៛៣៧) ចុះ ២៛៣៧ ដែលជាតម្លៃបោក ១ ស្ទិត ថ្លៃបោក ១ ស្ទិតត្រូវមាន ២៛៣៧ ប៉ុន្មានដង ចុះបោកដល់ទៅ ៣ ស្ទិតត្រូវជា ២៛៣៧ ប៉ុន្មានដង ។ (៣ ដង) ចូរសរសេរ ២៛៣៧ បីដងនៅលើក្ដារខៀន ។

សេចក្ដីរំលឹកសិស្ស: ត្រូវឲ្យចំណាំ ថា ៣ ជាចំនួនគត់ ហេតុនេះត្រូវសរសេរលេខ ៣ នៅក្រោមលេខ ២ ដែលជាចំនួនគត់ដូចគ្នា ។

របៀបធ្វើលេខ: គឺធ្វើដូចជាគុណចំនួនគត់នឹងគត់ដូចគ្នា គឺគុណពីស្ដាំមកឆ្វេង

៣ × ៧ = ២១ សរសេរ ១ ត្រាទុក ២ ៣ × ៣ = ៩ + ២ = ១១ សរសេរលេខ ១ ត្រាទុក ១
៣ × ២ = ៦ + ១ = ៧ សរុប ៧១១ ។

ក្នុងលេខតាំង មានលេខទសភាគ ២ ខ្ទង់ (៣ នឹង ៧) ហេតុនេះត្រូវរាប់ ២ ខ្ទង់ពីខាងស្ដាំមកឆ្វេង (ផលសរុប) ហើយដាក់កណ្ដាក់សញ្ញាត្រង់លេខ ២ ដែលជាខ្ទង់គត់ ។ ត្រូវរំលឹកសិស្សថា បើចំណែកទសភាគមានលេខ ៣ ខ្ទង់ ត្រូវរាប់ ៣ ខ្ទង់ពីស្ដាំមកឆ្វេង ហើយដាក់កណ្ដាក់សញ្ញា (ល)

ការហាត់លើក្ដារខៀន: សុំឲ្យសិស្សធ្វើបានច្រើន:

ក) ១៣ ល.១៧ × ៥ = . = ២៧គ. ក ០៥៩ × ១៣ = . – ១០៧, ម ១២៨ × ២១៤ =

ខ) បំណោទងាយៗ = ខ្សែមួយកំណាត់ប្រវែង ១,ម ២៥ ចុះបើខ្សែ ៧ កំណាត់ប្រវែងប៉ុន្មាន ។

ខ្មៅដៃមួយថ្លៃ ២៛ ១៥ ចុះបើខ្មៅដៃ ១ ឡូ (១២) ថ្លៃប៉ុន្មាន ល។

ការហាត់សរសេរ: សុំលោកគ្រូលៃលកជ្រើសរើសជាកឲ្យសិស្សធ្វើផងចុះ ។

## អាទិត្យទី ២ លេខគុណចំនួនទសភាគ (ត)

លេខតាំង ២ សុទ្ធតែចំនួនទសភាគទាំងអស់ (Les deux factures sont décimance)

បំណោទផ្ដើម: ស្រីម្នាក់ទិញទេសឯកទៅ ៣ម,៥០ ថ្លៃក្នុង ១ ម៉ែត្រ ១៦រ,៣៥ តើស្រីនោះចំណាយអស់ប៉ុន្មាន ។

របៀបពន្យល់: របៀបពន្យល់ចំណោទសុំធ្វើដូចមុន ប៉ុន្តែដល់ឲ្យធ្វើលេខ សុំរំលឹកសិស្សឲ្យប្រយ័ត្នត្រង់ខ្ទង់កណ្ដក់សញ្ញា ពេលដែលឲ្យរៀបលេខគុណធ្វើ ត្រូវប្រយ័ត្នឲ្យវាសរសេរលេខត្រង់ជួរពីលើមកក្រោម គឺខ្ទង់គត់ក្រោមខ្ទង់គត់ ខ្ទង់ទសភាគឲ្យត្រង់ជួរក្រោមខ្ទង់ទសភាគ។ លុះដល់ធ្វើលេខរួចហើយ គេរាប់ចំនួនលេខទសភាគដែលមាននៅក្នុងសព្វទាំង ២ រួចរាប់លេខក្នុងផលរួមមកពីស្ដាំមកឆ្វេង ហើយដាក់កណ្ដក់សញ្ញា ។

ឧបមា: ចម្លើយចំណោទខាងលើនេះ គឺផលរួមមកគឺ ៥៧២២៥ ក្នុងសព្វទាំងពីរមានលេខទសភាគ ៣ ខ្ទង់ (លុបសូន្យចោល) ឲ្យរាប់ពីស្ដាំមកឆ្វេងចាប់ពីលេខ ៥ មក ដូចនេះត្រូវដាក់កណ្ដក់សញ្ញាខាងស្ដាំលេខ ៧ ឆ្លើយថាស្រីនោះចំណាយអស់ ៥៧រ,២២៥ ឬ ៥៧រ,២៥ ។

ការបញ្ជាក់លើការផ្ទួន: សុំឲ្យសិស្សធ្វើឲ្យបានច្រើន

៨៣រ,៧២ × ២០,៤ = .— ៩៥ល,៣៤ × ៥,២៦ = .— ១០៩គ.ក,០៧៦ × ៣,១២៥ = .—

ហាត់សរសេរ: ចំណោទ ដើម្បីនឹងដេរអាវទ្រនាប់ ២ មនុស្សម្នាក់ទិញទេសឯកស ៣ម,១៥ ថ្លៃក្នុង ១ ម៉ែត្រ ១៧រ,៣៥ ប្រដាប់ប្រដាផ្សេងៗ (ខ្សែរ អម្ជុល) អស់ ៤រ,៥០ ឈ្នួលជាងដេរក្នុងអាវមួយអស់ ២៣រ,៨០.— តើអ្នកនោះចំណាយទៅក្នុងអាវទ្រនាប់មួយអស់ប៉ុន្មានរៀល ។

## អាទិត្យទី ៣.— អំពីលេខសងចំនួនអនិយមភាគ

បំណោទផ្ដើម: ក) រថយន្តមួយចេញពីភ្នំពេញទៅតាខ្មៅពីម៉ោង ៨,១៥ មីនុត បើកទៅដល់ដំណាក់ (តាខ្មៅ) នៅពេលម៉ោង ៩,៣៩ មីនុត តើរថយន្តនោះរត់ប៉ុន្មានម៉ោងទើបដល់ដំណាក់ចត ។

របៀបពន្យល់ : សុំលោកគ្រូយកមុខនាឡិកាមកឲ្យសិស្សដាក់ម៉ោងដែលរថយន្តចេញ រួចពេលដែលវាទៅដល់ដំណាក់ ហើយឲ្យរាប់មើល តើរទេះឡានបើកប៉ុន្មានម៉ោងទើបដល់ (១ម៉,២៤) ចុះនឹងគិតឲ្យឃើញ ១ម៉,១៤ តើត្រូវធ្វើលេខអ្វី ។ ឲ្យរៀបលេខធ្វើ រួចឲ្យរកវិធាន ។

ការហាត់បញ្ជាក់លើក្ដារខៀន : ៦ម៉,៤៩ – ៤ម៉,២៣ = . – ៩ម៉,៤៨ – ៦ម៉,៣៥ = . – ១៣ម៉,៥៣ – ១២ម៉,៣២ = (ឲ្យធ្វើឲ្យច្រើន) ។

រទេះភ្លើងចេញពីពោធិ៍សាត់នៅពេលម៉ោង ៧,៣៥ ទៅដល់បាត់ដំបងនៅពេលម៉ោង ៨,២៥ តើរទេះភ្លើងនោះបើកប៉ុន្មានម៉ោងទើបដល់បាត់ដំបង ។

១) ភ្លៀង ១ មេចាប់ធ្លាក់ពីពេលម៉ោង ២,១៥ ហើយរាំងបាត់ទៅវិញពេលម៉ោង ៣,០៥ តើភ្លៀង ១ មេនោះធ្លាក់ក្នុងប៉ុន្មានម៉ោង ។

របៀបពន្យល់ : ត្រូវធ្វើដូចពន្យល់ចំណោទមុន ប៉ុន្តែរបៀបធ្វើលេខខុសគ្នា ។

គឺថា : ត្រូវ ៣ម៉,០៨ – ២ម៉,១៥ =

របៀបធ្វើលេខ :

| | |
|---|---|
| ២ម៉,៦៨ | បែកខាងខ្ទង់មីនុត ចំនួនធំ |
| ២ម៉,១៥ | តិចជាងចំនួនតូច ៨ម.ន. |
| ០, ១៣ | តិចជាង ១៥ ម.ន. |

ហេតុនេះ ត្រូវដក ១ ម៉ោងពី ៣ ម៉ោង ហើយបំបែកឲ្យទៅជាមីនុត រួចយកទៅបន្ថែមលើខ្ទង់មីនុត ១ម៉ = ៦០ ម.ន. + ៨ = ម.ន. = ៦៨ ម.ន. បើដូចនេះ ៣ម៉,០៨ ដល់បំបែកទៅត្រូវជា ២ម៉,៦៨ ទើបធ្វើលេខបាន គឺថា ៦៨ ម.ន – ១៥ម.ន. = ៥៣ ម.ន ២ម៉ – ២ម៉ = ០

ឆ្លើយថា = ភ្លៀង ១ មេនោះធ្លាក់ក្នុងកំឡុង ៥៣ មីនុត

ការហាត់សរសេរ ចំណោទ មានថ្មើរម្នាក់ចេញពីផ្ទះទៅនៅពេលម៉ោង ៧ កន្លះទៅដល់ពោធិចិនតុងនៅពេលម៉ោង ១១, ៤២ តើអ្នកនោះដើរប៉ុន្មានម៉ោង ។

# វង្វាស់វង្វាល់

## អាទិត្យទី ១.— អំពីហ្វ្រង់

**វត្ថុដែលត្រូវយកមកបង្ហាញ**: ផ្ទាំងគំនូរវង្វាស់វង្វាល់ ។

**របៀបបង្រៀន**.— បង្ហាញគំនូររូបិយវត្ថុបារាំងនៅក្នុងសៀវភៅនព្វន្ត លោក-(ឡឺម៉ូអាន) ថ្នាក់បដិញ្ញាណដ្ឋាននិងមធ្យមដ្ឋានទំព័រ ១៦២-១៦៣-១៦៤-១៦៥ រូបិយវត្ថុប្រធាននៃប្រទេសបារាំងសេសគឺហ្វ្រង់ សរសេរកាត់ថា (ហ្វ្រ) ១៧ ហ្វ្រង់ស្មើនឹងថ្លៃរូបិយវត្ថុយើង ១ រៀល ។

**រូបិយវត្ថុបារាំងមានអ្វីខ្លះ**: ១) រូបិយវត្ថុធ្វើអំពីលោហធាតុ ។

ក) អំពីសំរិទ្ធ (bronze) ១ សង្ទីម ៥ សង្ទីម ១០ សង្ទីម

ខ) អំពីកល់មាំង ២៥ សង្ទីម ១០ ស. ៥ ស.

គ) អំពីអាលុយមីនីញូម ៥០ ស. ១ ហ្វ្រង់ ២ ហ្វ្រង់

ឃ) អំពីប្រាក់ ១០ ហ្វ្រង់ ២០ ហ្វ្រង់

ង) អំពីមាស ១០០ ហ្វ្រង់

២) រូបិយវត្ថុធ្វើអំពីក្រដាស = ក្រដាស ៥០ ហ្វ្រង់ ៥០០ ហ្វ្រ ១០០០ ហ្វ្រ

## អាទិត្យទី ២ – អំពីថ្លៃនៃរូបិយវត្ថុបារាំង =

**របៀបបង្រៀន** = ហ្វ្រង់មានរូបិយវត្ថុដែលមានថ្លៃតិចជាងពីរយ៉ាងគឺ ដេស៊ីមនិងសង្ទីម

ដេស៊ីមថ្លៃតិចជាងហ្វ្រង់ ១០ ដង ហេតុនេះ ១ ហ្វ្រង់មាន ១០ ដ សរសេរ ០ ហ្វ្រ ១ ដេស៊ីម សរសេរមួយខ្ទង់ខាងស្តាំហ្វ្រង់ (ស្តាំកណ្តាក់សញ្ញា) ឧបមា ២ ហ្វ្រង់ ៥ ដេស៊ីម សរសេរ ២ ហ្វ្រ ៥

សង្ទីមថ្លៃតិចជាងហ្វ្រង់ ១០០ ដង ហេតុនេះ ១ ហ្វ្រង់មាន ១០០ ស. ០ ហ្វ្រ ០១ សង្ទីម សរសេរ ២ ខ្ទង់ខាងស្តាំហ្វ្រង់ (ស្តាំកណ្តាក់សញ្ញា) ឧបមា ៣ ហ្វ្រ ៤ សង្ទីម សរសេរ ៣ ហ្វ្រ ០៤

**ការហាត់បញ្ជាក់** = ៤ ហ្វ្រង់មានប៉ុន្មានដេស៊ីម ។ សង្ទីម ។ ៧៩ ដេស៊ីមត្រូវជា ប៉ុន្មានហ្វ្រង់ ។ ១៧៨ សង្ទីមត្រូវជាប៉ុន្មានដេស៊ីម ។ ប៉ុន្មានហ្វ្រង់ ។ល។

**ការហាត់សរសេរ** = ចូរធ្វើលេខខាងក្រោមនេះ ។

១៣ ហ្វ្រ ៧១ ស + ២៩ ហ្វ្រ ៨ ស + ៣៥ ហ្វ្រ ៩ ដ = ..... ដេស៊ីម

២៩៨ ស − ៣ ដ ៩ = ...... ហ្វ្រង់

៦៥ ហ្វ្រ ០៧ × ៣៥ = ...... ដេស៊ីម ឬ ...... សង្ទីម

**បំណោទ** = សិស្សម្នាក់ផ្ញើទិញសៀវភៅមួយពីស្រុកបារាំងថ្លៃ ២៣៧ ហ្វ្រ ៥០ វាត្រូវចេញថ្លៃផ្ញើសៀវភៅ ២៥ ហ្វ្រ ១៥ ប្រៃសនីយយកពន្ធ ១៣ ហ្វ្រ ៣៥ តើសិស្សនោះចំណាយអស់ប៉ុន្មានរៀល បើរូបិយវត្ថុបារាំង ១៧ ហ្វ្រង់ ស្មើនឹងថ្លៃប្រាក់យើង ១ រៀល ។

## អាទិត្យទី ៣.– អំពីរូបិយវត្ថុស្រុកអាយ (ប្រទេសឥណ្ឌូចិន)

**របស់ដែលត្រូវយកមកបង្រៀន** = ប្រាក់ ១ រៀល ក្រដាស ១ រៀល គ្រប់យ៉ាង ជាន់ដើមនឹងចេញថ្មី ក្រដាស ៥ រ ក្រដាស ១០ រ ក្រដាស ២០ រ (ជាន់ចាស់នឹងថ្មី) ក្រដាស ៥០ រ ក្រដាស ១០០ រ (ចាស់នឹងថ្មី) ក្រដាស ៥០ សេន ក្រដាស ២០ ស. ក្រដាស ១០ ស. ក្រដាស ៥ ស. ។

រូបិយវត្ថុធ្វើអំពីលោហធាតុ = ប្រាក់ ៥០ ស. ប្រាក់ ២០ ស. ប្រាក់ ១០ ស. លុយ ៥ ស. លុយ ១ ស. (បើរកបាន សុំឲ្យយកលុយ ២ សេននឹង ១ សេនមកបង្ហាញឲ្យសិស្សស្គាល់ផង ។

**របៀបបង្រៀន** = នឹងសងថ្លៃទំនិញ គេត្រូវការនឹងរូបិយវត្ថុ រូបិយវត្ថុ ដែលមាននៅនាប្រទេសឥណ្ឌូចិនគឺរៀល សរសេរកាត់ (រ) (បង្ហាញឲ្យមើល) រៀលមានប៉ុន្មានយ៉ាង ។ ហេតុអ្វីបានជាគេធ្វើរូបិយវត្ថុអំពីក្រដាសផង ។ ១ រៀលមានថ្លៃស្មើនឹង ១៧ ហ្វ្រង់បារាំង ។

**ថ្លៃនៃរូបិយវត្ថុស្រុកអាយ** ១) រូបិយវត្ថុថ្លៃច្រើនជាង ១ រៀល ឲ្យសិស្សយកក្រដាសប្រាក់គ្រប់យ៉ាងមករាប់មើល ២) រូបិយវត្ថុថ្លៃតិចជាង ១ រៀល ឲ្យសិស្សរាប់ ។

**ការហាត់ឱ្យបេះប្រើប្រាស់** = ឱ្យសិស្សដូររូបិយវត្ថុ ដូរឯកត្តួរក្រដាស ១០០រ នេះឱ្យមានក្រដាស ៥០រ ខ្លះ ២០រ ខ្លះ ១០រ ខ្លះ ៥រ ខ្លះ ១រ ខ្លះ ។

**ការហាត់លើការជួញ** = មនុស្សម្នាក់ទិញស្បែកជើង ១ សំរាប់ថ្លៃ ១៩៥រ ស្រោមជើង ១ គូថ្លៃ ៣៧រ អ្នកនោះឱ្យក្រដាស ១០០រ បីសន្លឹកទៅឈ្មួញ តើឈ្មួញថែមក្រដាសប្រាក់អ្វីខ្លះមកវិញ ។

**ការហាត់សរសេរ** = ដើម្បីនឹងសងថ្លៃទំនិញ ៧០ រៀល ខ្ញុំឱ្យក្រដាស ៥រ..... សន្លឹកក៏បាន ។ ក្រដាស ២០រ..... សន្លឹកនឹងក្រដាស ៥រ..... សន្លឹកក៏បាន ។

បើសិនណាខ្ញុំឱ្យក្រដាស ១០០រ ទៅឈ្មួញ ៗ នោះត្រូវថែមក្រដាស ៥រ..... សន្លឹកមកខ្ញុំវិញ ។ ឬក្រដាស ២០រ..... សន្លឹកហើយនឹងក្រដាស ៥រ..... សន្លឹកមកខ្ញុំវិញក៏បាន ។

## ធរណីមាណសាស្ត្រ

## អំពីត្រីកោណ (ត) ការគិតគួររកផ្ទៃក្រឡា រកបាតនិងកំពស់

### អាទិត្យទី ១— ការគិតគួររកផ្ទៃក្រឡា




*របស់ដែលត្រូវយកមកបង្រៀន.— សុំយកក្រដាសក្រាស់មួយបន្ទះមកកាត់ជាការបួនជ្រុងព្នាយស្រួចមួយ បាតប្រវែង ៨ សង់ទីម៉ែត្រ កំពស់ ៤ សង់ទីម៉ែត្រ ហើយកាត់ត្រីកោណមួយចំហៀងនឹងពាក់កណ្ដាលបួនជ្រុងព្នាយស្រួចខាងលើនេះ ។*

របៀបបង្រៀន. — ឲ្យសិស្សវាស់កំពស់ បាតនៃបួនជ្រុងព្នាយស្រប




រួចឲ្យវាបត់ចតុរង្សនេះជាពីរតាមកំពូលមុម ហើយសួរថា បើគេបែកបួនជ្រុងព្នាយស្រប ជាពីរ តើចតុរង្សនោះកើតបានទៅជាអ្វី ។ ត្រីកោណពីរ ។ ត្រីកោណទាំងពីរនោះមានសណ្ឋានយ៉ាងណា ។ ទំហំស្មើគ្នា ។ ឲ្យពិនិត្យបាតត្រីកោណទាំងពីរ ។ ស្មើនឹងបាតបួនជ្រុងព្នាយស្រប ។ រួចឲ្យវាយកត្រីកោណដែលកាត់ ទៅដាក់ផ្គុំពីលើត្រីកោណដែលកើតចេញពីបួនជ្រុងព្នាយស្របដែលបត់ ។ ដូច្នេះត្រីកោណនឹងបួនជ្រុងព្នាយស្របវាយ៉ាងដូចម្ដេចនឹងគ្នា ។ ត្រីកោណត្រូវជាពាក់កណ្ដាលបួនជ្រុងព្នាយស្រប ។ ចុះបាត ។ ប្រវែងស្មើគ្នា ។

ហេតុនេះនឹងរកផ្ទៃក្រឡានៃត្រីកោណ តើធ្វើដូចម្ដេច ។ គុណបាតនឹងពាក់កណ្ដាលកំពស់ $( ប \times \frac{ក}{២} )$ ឬពាក់កណ្ដាលបាតនឹងកំពស់ $( \frac{ប}{២} + ក )$ ឬគុណបាតនឹងកំពស់ រួចបែកផលជាពីរ $( \frac{ប + ក}{២} )$

ឧបមា ត្រីកោណមួយបាតប្រវែង ៨ សង់ទីម៉ែត្រ កំពស់ ៤ ស.ម. តើត្រីកោណនោះមានផ្ទៃទំហំប៉ុន្មានសង់ទីម៉ែត្រក្រឡា ។

របៀបគិតលេខ: ១) បាត់ ៨ ស.ម គុណនឹងពាក់កណ្ដាលកំពស់ ៤ ស.ម/២ ស.ម ត្រូវជា ១៦ ស.ម$^{២}$ ។ ២) ពាក់កណ្ដាលបាត $\frac{៨}{២}$ ស.ម = ៤ ស.ម$^{២}$ គុណនឹងកំពស់ ៤ ស.ម ត្រូវជា ១៦ ស.ម.$^{២}$ ។ ៣) បាត ៨ ស.ម គុណនឹងកំពស់ ៤ ស.ម ត្រូវជា ៣២ ស.ម$^{២}$ ចែកនឹង ២ ត្រូវជា ១៦ ស.ម$^{២}$

## ការហាត់ដោយបញ្ញា.— សុំធ្វើឲ្យបានច្រើន

ស្រែមួយរាងត្រីកោណបាតប្រវែង ១០ ម៉, កំពស់ ៦ ម៉, តើទំហំស្រែនោះប៉ុន្មានម៉ែត្រក្រឡា ។ ចំការមួយរាងត្រីកោណ បាតប្រវែង ១៦ ម៉. កំពស់ ៨ ម៉. តើចំការនោះមានប៉ុន្មានម៉ែត្រក្រឡា ។

## ការហាត់លើក្ដារខ្មៀន.— ដី ១ ក្បាលរាងជាត្រីកោណ បាតប្រវែង ១៩៦ ម៉. កំពស់៨៤ម តើទំហំដីនោះមានប៉ុន្មានម៉ែត្រក្រឡា ។

គេទិញស្រែមួយរាងជាត្រីកោណ បាតប្រវែង ២១៨ ម៉ កំពស់ ១០២ ម៉ ថ្លៃក្នុង ១ ម៉ែត្រក្រឡា ៣២ រៀល តើគេចំណាយអស់ប្រាក់ប៉ុន្មានរៀល ។

## ការហាត់សរសេរ.— មនុស្សម្នាក់ទិញដីមួយក្បាល រាងជាត្រីស្មើជ្រុងទាំងបី បាតប្រវែង ២៣៤ ម៉ កំពស់ ១២២ ម៉. ថ្លៃក្នុង ១ ម៉ែត្រក្រឡា ៤ ៛៥០ គេធ្វើរបងព័ទ្ធជុំវិញ ថ្លៃក្នុង ១ ម៉ែត្រ ១៨ ៛៧៥ តើអ្នកនោះចំណាយទាំងអស់ប៉ុន្មាន ។

# អាទិត្យទី ២ ការគិតគូររកបាត

## ឧទាហរណ៍.— ដីមួយរាងត្រីកោណ ផ្ទៃក្រឡាទំហំ ២៧០ ម៉$^{២}$ កំពស់ប្រវែង ១២ ម៉ តើបាតដីនោះប្រវែងប៉ុន្មានម៉ែត្រ

## របៀបគិតលេខ.— ចែកផ្ទៃនឹងពាក់កណ្ដាលកំពស់= ផ្ទៃ ២៧០ម៉$^{២}$ ចែកនឹង ពាក់កណ្ដាលកំពស់ $\frac{១២}{២}$ ម៉ ៦ ម៉ ៤៥ម

## ការបញ្ជាក់ឲ្យឃើញខុសត្រូវ.— គិតរកឲ្យឃើញផ្ទៃក្រឡាឡើងវិញ គុណ បាត ៤៥ ម៉ នឹងពាក់កណ្ដាលកំរស់ $\frac{១២}{២}$ម ២៧០ ម៉$^{២}$

## ការហាត់បញ្ជាក់= សុំឲ្យធ្វើឲ្យបានច្រើន.— ស្រែ ១ រាងជាត្រីកោណ ផ្ទៃក្រឡា ៧៦៨ ម៉ កំពស់ប្រវែង ១៣០ ម៉ តើស្រែនោះប្រវែងប៉ុន្មាន ។ ចំការ ១ រាងត្រីកោណ មានផ្ទៃក្រឡាទំហំ ១២៣០ ម៉$^{២}$ កំពស់ ៣១០ តើបាតចំការនោះប្រវែងប៉ុន្មាន ។ល។

**ការហាត់សរសេរ.—** ចំការ ១ នឹងស្រែ ១ ទំហំប៉ុនគ្នា ផ្ទៃក្រឡាមាន ២៤០០ម៉$^{២}$ ចំការរាងជាបួនជ្រុងព្នាយស្រប បាតប្រវែង ៤៨ម៉ កំពស់ ២៥ម៉ តើបាតស្រែដែលរាងជាត្រីកោណ មានប្រវែងប៉ុន្មាន បើកំពស់វាប្រវែង ៦០ម៉ ។

## អាទិត្យទី ៣ ការគិតរកកំពស់

**ឧទាហរណ៍.—** សួនមួយរាងជាត្រីកោណ ទំហំមាន ៩៦០ម៉ បាតប្រវែង ១២០ម៉ តើកំពស់សួននោះប្រវែងប៉ុន្មាន ។

**របៀបគិតលេខ.—** ចែកផ្ទៃក្រឡានឹងពាក់កណ្ដាលបាត ផ្ទៃ ៩៦០ម៉$^{២}$ ចែកនឹង ពាក់កណ្ដាលបាត $\frac{១២០}{២}$ម៉ ឬ ៦០ម៉ ត្រូវជា ១៦ម

**ការបញ្ជាក់ឲ្យឃើញខុសត្រូវ.—** រកឲ្យឃើញផ្ទៃក្រឡាឡើងវិញ គឺគុណ បាត ១២០ ម នឹងពាក់កណ្ដាលកំពស់ $\frac{១៦}{២}$ម ឬ ៨ ម ត្រូវជា ៩៦០ ម$^{២}$

**ការហាត់បញ្ជាក់.—** សុំឲ្យសិស្សធ្វើឲ្យបានច្រើន

**ការហាត់សរសេរ.—** គេដូរដីបួនជ្រុងទ្រវែងមួយនឹងស្រែមួយរាងត្រីកោណ ទំហំស្មើគ្នា មាន ២៦៤៦ម$^{២}$ បណ្ដាប ដីបួនជ្រុងទ្រវែង ប្រវែង ៤៩ម៉ ទទឹង ២៧ម៉ បាតស្រែប្រវែង ៥៤ តើកំពស់ស្រែនោះប្រវែងប៉ុន្មានម៉ែត្រ ។

អាធិកដ្ឋាន

## នព្វន្ត

### មេរៀនទី ១.— លេខគុណនឹង ១០-១០០-១០០០

សៀវភៅមួយមាន ១៦ សន្លឹក ។ តើសៀវភៅ ១០ ។ សៀវភៅ ១០០ ។ សៀវភៅ ១០០០ មានប៉ុន្មានសន្លឹក ។

ដើម្បីនឹងរកចំនួនសន្លឹកដែលមាននៅក្នុងសៀវភៅ ១០ សៀវភៅ ១០០ សៀវភៅ ១០០០; ត្រូវយកចំនួនសន្លឹកគុណនឹងសៀវភៅ ១០ ។ ១០០ ។ ១០០០ ។ គឺ.

១៦ ស × ១០ =     ១៦ ស × ១០០ =     ១៦ ស × ១០០ =

## សេចក្ដីសំខាន់.– ដើម្បីនឹងគុណចំនួនណានឹង ១០ ។ ១០០ ។ ១០០០

គេមិនបាច់ធ្វើលេខគុណទេ គេគ្រាន់តែថែមនៅស្ដាំចំនួននោះ សូន្យមួយ បើគុណនឹង១០ ។ សូន្យពីរ បើគុណនឹង១០០ ។ សូន្យបី បើគុណនឹង១០០០ (ល)

១៦ × ១០ = ១៦០; ១៦ × ១០០ = ១៦០០; ១៦ × ១០០០ = ១៦០០០

## វិធីហាត់គិតមាត់ទទេ.– ត្រូវជាប៉ុន្មាន

ផ្លែស្វាយ ៣ ដប់ដន ។ ផ្លែត្រប់ ៤ ដប់ដន ។ ផ្លែដូង ២៥ ដប់ដន សំពត់មួយម៉ែត្រថ្លៃ ១៥ រ; តើថ្លៃប៉ុន្មានសំពត់ ១០ ម ។ ១០០ ម ។ ១០០០ ម ។ គោញីមួយថ្លៃ ២៥០ រ; តើគោញី ១០០ ថ្លៃប៉ុន្មាន ។ ក្នុងមួយថ្ងៃម្ដាយខ្ញុំសន្សំ ៧៥ រ; តើក្នុងមួយ ១០០០ ថ្ងៃគាត់សន្សំបានប៉ុន្មានរៀល ។

## វិធីហាត់សរសេរ –១– ចូរធ្វើលេខខាងក្រោមនេះ

១២ រ × ១០ = ; ១៥ ល × ១០០ = ; ២៣ ស × ១០០០ = ; ៥ × = ៥០ ស

២៥ រ × ១០ = ; ៣៦ ល × ១០០ = ; ៤៥ រ × ១០០០ = ; ៣៤ រ × = ៣៤ រ

៣ រ × ១០ = ; ៩ × ១០០ = ; ៥៣ × ១០០០ = ; ៨ × = ៨០០ រ

## មេរៀនទី ២ – លេខគុណចំនួនបែងភាគគត់ ១០–១០០–១០០០

ដងប៉ាកកាមួយថ្លៃ ៣រ,៥០ តើដងប៉ាកកា ១០-១០០-១០០០ ថ្លៃប៉ុន្មាន ដើម្បីនឹងរកថ្លៃដងប៉ាកកា ១០-១០០-១០០០ ត្រូវយកថ្លៃដងប៉ាកកាមួយគុណនឹងចំនួនដងប៉ាកកា ១០-១០០-១០០០ គឺៈ ៣រ,៥០ × ១០= ៣រ,៥០ × ១០០ = ៣រ,៥០ × ១០០០ = ;

**សេចក្ដីសំខាន់ .—** ដើម្បីនឹងគុណរកចំនួនលេខថែនភាគពេញ ១០-១០០-១០០០ គេត្រូវរំកិលកណ្ដក់សញ្ញាទៅខាងស្ដាំមួយខ្ទង់បើគុណនឹង ១០ ពីរខ្ទង់បើគុណនឹង ១០០ បីខ្ទង់ បើគុណនឹង ១០០០ ។

ឧបមា ៣រ,៥០ × ១០ = ៣៥រ,០០ ៣,៥០ × ១០០ = ៣៥០រ,០០ ៣រ,៥០ × ១០០០ = ៣៥០០រ,០០

## វិធីហាត់មាត់ទទេ .— ត្រូវជាប៉ុន្មាន

គុណនឹង ១០ ៥រ,៦២ ; ៣០ម,៤ ; ៥៣ល,៨១ ; ២៥,៧០ ។

គុណនឹង ១០០ ៣១រ,៧០ ; ៤ម,០៨៣ ; ០ស,៩៣៧ ; ២១ម,០០៦ ។

គុណនឹង ១០០០ ០រ,៥៨ ; ៥ម,៤០៨; ៣ល,០០៦; ២៥រ,០៧ ;

សៀវភៅមួយថ្លៃ ១រ,៥៥ តើសៀវភៅ ១០០ ថ្លៃប៉ុន្មាន ។

ស្ករសមួយគីឡូក្រាមថ្លៃ ១១,៨៥ តើ ១០គីឡូក្រាមថ្លៃប៉ុន្មាន ។

ខ្សែលួសមួយម៉ែត្រថ្លៃ ០រ,៩៨ តើ ១០០០ ម៉ែត្រថ្លៃប៉ុន្មាន ។

## វិធីហាត់សរសេរ .— ចំណោទ

ជាងដេរសំលៀកបំពាក់ម្នាក់ទិញសំពត់ជាឱបចំនួន ១០០០ ម៉ែត្រ ថ្លៃក្នុងមួយម៉ែត្រ ១២រ,០៨ ហើយនឹងសំពត់សាក្លាតចំនួន ១០ម, ថ្លៃ ៨៥រ, ក្នុងមួយម៉ែត្រ ។ តើគេត្រូវថែមមកវិញប៉ុន្មាន បើជាងនោះឲ្យក្រដាសប្រាក់ ១០០ ចំនួន ៧ សន្លឹកទៅអ្នកលក់សំពត់ ។

# មេរៀនទី ៣ .– លេខដុំគុណនឹងចំនួនបែងភាគគត់

| | | |
|---|---|---|
| ២៥៨ × ៤,១៣ | ២០,៣២ × ២,៥៩ | នឹងធ្វើលេខគុណចំនួនភាគគត់ |
| ៧៧៤ | ២០ ៣២ | ទី –១– គេសរសេរចំនួនទាំងពីរ |
| + ២៥៨ | + ១០១៦ ០ | នោះ មួយលើមួយក្រោម |
| ១០៣២ | ៤០៦៤ | |
| ១០៦៥,៥៤ | ៥១,០០៣២ | |

ហើយគុណដូចជាចំនួនដុំដែរ ឥតមានអារម្មណ៍នឹងកណ្ដក់សញ្ញាឡើយ ។

២– គេត្រូវដាក់សញ្ញានៅខាងស្ដាំលំដួ តាមចំនួនលេខបែងភាគ ដែលមាននៅក្នុងចំនួនដំណាំងនឹងមេគុណ ។

វិធីហាត់មាត់ទទេ.– ខ្សែលួសមួយបន្ទាយមាន ១២ម៉ែត្រ ៣០ តើខ្សែលួស ៥ បន្ទាយមានប៉ុន្មានម៉ែត្រ ។

អង្ករមួយកំប៉ុងថ្លៃ ២៛,៦៥ តើ ៤ កំប៉ុងថ្លៃប៉ុន្មាន ។

សំពត់មួយម៉ែត្រថ្លៃ ១៣៛,២០ តើសំពត់ ៣ម៥០ ថ្លៃប៉ុន្មាន ។

ម្សៅមួយគីឡូក្រាមថ្លៃ ០៛,៣៥ តើ ៣ គ.ក្រ.៧៤ ថ្លៃប៉ុន្មាន ។

វិធីហាត់សរសេរ– ចូរធ្វើលេខខាងក្រោមនេះ

២៥៨ × ១៤,៣=; ៤៥៧ × ២, ៤៥=; ១២០.៣០ × ១៣.៣០

៨៨៛០៤ × ២,៤=; ៦៥២ × ០, ៣៥១= ១២៨៩, ១៣ × ១, ៥១៣

បំណោទ ជាងអារឈើ ១៨ នាក់ ធ្វើការក្នុងរោងអារឈើ ក្នុងមួយថ្ងៃម្នាក់ៗ បានឈ្នួល ០៛៧៥ ជាងអារទាំងអស់នោះធ្វើការ ៣១២ ថ្ងៃ ក្នុង១ឆ្នាំ តើប្រាក់ឈ្នួលជាងអារនោះប៉ុន្មានក្នុង ១ឆ្នាំ ។

# រង្វាស់រង្វាល់

## ហ្វ្រង់ - សង្ទីម

មេរៀនទី ១— សូមយកផ្ទាំងគំរូរង្វាស់រង្វាល់ដែលមានរូបិយវត្ថុគឺ ហ្វ្រង់-សង្ទីម ។ល។ មកបង្ហាញសិស្សឲ្យឃើញជាក់ច្បាស់ រួចហើយប្រាប់ថា នៅប្រទេសយើង គេចាយប្រាក់រៀល ។ ក្នុងរៀលមួយៗ មានប្រាក់សម្រាប់ចាយផ្សេងៗពីគ្នា ដូចប្រាក់រៀលចាយសព្វថ្ងៃនេះ មិនមែនដូចប្រាក់ដែលគេចាយនៅនគរសៀមទេ ។ ឯចំណែកនៅស្រុកបារាំងសែសវិញ ចេញឲ្យថ្លៃទំនិញដែលគេទិញនោះត្រូវឲ្យជាហ្វ្រង់ ។ ហ្វ្រង់នេះគឺមេរូបិយវត្ថុនៅនគរបារាំងសែស គេសរសេរកាត់ហ្វ: ។ ដូចណាមានមនុស្សនៅនគរយើងនេះទិញទំនិញនៅស្រុកបារាំងសែស មនុស្សនេះត្រូវចេញថ្លៃជាចំនួនហ្វ្រង់ ដើម្បីនឹងឲ្យបានប្រាក់ហ្វ្រង់នោះ គេត្រូវប្តូរប្រាក់រៀលយើងនឹងប្រាក់ហ្វ្រង់ សព្វថ្ងៃនេះកាលណាគេយកប្រាក់ ១ រៀលទៅ គេដូរបានជា ១៧ ហ្វ្រង់ ហេតុនេះគេដឹងថាក្នុង ១ រៀលយើងមានដំឡៃ ១៧ ហ្វ្រង់ ។ ឯការប្តូរគ្នាបានតែនៅផ្ទះបង្គាប្រាក់ ឬនៅផ្ទះខ្សែល្ហួស បើគេផ្ញើទៅទិញទំនិញនៅស្រុកបារាំងសែស ការគយពីហ្វ្រង់ គឺសង្ទីម នៅក្នុងចំនួនហ្វ្រង់សង្ទីម ត្រូវសរសេរនៅខ្ទង់ទី ២ ខាងស្តាំកណ្តក់សញ្ញា ។

វិធីហាត់គិតមាត់ទទេ– កន្លះហ្វ្រង់ត្រូវជាប៉ុន្មានសង់ទីម ? មួយហ្វ្រង់ត្រូវជាប៉ុន្មានសង់ទីម ? ៣ហ្វ្រង់កន្លះត្រូវជាប៉ុន្មានសង់ទីម ? ១២ហ្វ្រង់ត្រូវជាប៉ុន្មានសង់ទីម ? ល ? ១០០សង់ទីមត្រូវជាប៉ុន្មានហ្វ្រង់ ? ៤០០សង់ទីមត្រូវជាប៉ុន្មានហ្វ្រង់ ? ៦៧០ សង់ទីមត្រូវជាប៉ុន្មានហ្វ្រង់ ? ដំរៃប្រាក់រៀល គឺ ១៧ហ្វ្រង់ ចូរគិតជាហ្វ្រង់ត្រូវបានប៉ុន្មាន បើប្រាក់ ៦៛, ? ៨៛, ? ១៣៛, ? ៥០៛, ? ល ? ដំរៃប្រាក់រៀល គឺ ១៧ហ្វ្រង់ត្រូវបានប៉ុន្មាន បើ២០ហ្វ្រង់ ? ១៥ហ្វ្រង់ ? ៦៧ហ្វ្រង់ ? ៥៥ហ្វ្រង់ ? ៣២០ហ្វ្រង់ ? ៤៨០ហ្វ្រង់ ?

បំណោទ– ១ នៅផ្ទះលក់សៀវភៅមួយ គេទិញសៀវភៅមើល ២ ថ្លៃ ៨ ហ្វ្រង់មួយ និងសៀវភៅមើលមួយទៀត ថ្លៃ ១៨ហ្វ្រង់ បើដំរៃប្រាក់រៀល ២០ហ្វ្រង់ ខ្ញុំត្រូវឲ្យប៉ុន្មានរៀលទៅអ្នកលក់សៀវភៅនោះ ? ២- ក្នុងហាងបារាំងមួយមានត្រែឈើមួយ គេដាក់ថ្លៃ ៧០៛, ត្រែរេកមួយ ១៨០០ ហ្វ្រង់ ដំរៃប្រាក់ ១៧ ហ្វ្រង់ តើត្រែណាថ្លៃជាងគេ ?

មេរៀនទី ២– រៀនសាអំពីរង្វាស់បណ្ដោយ ម៉ែត្រ និង ដេកាម៉ែត្រ សូមតែងធ្វើឲ្យគ្រប់សេចក្ដីផ្សេងៗ ដូចខែមុនៗមក ។

មេរៀនទី ៣– រៀនសាពីហិកតូម៉ែត្រ និង គីឡូម៉ែត្រ ។

មេរៀនទី ៤– រៀនសាអំពីដេស៊ីម៉ែត្រ សង់ទីម៉ែត្រ មិល្លីម៉ែត្រ ។

# គណិត

## បរិច្ឆណដ្ឋាន

តាមរបៀបថ្មីនៃវិជ្ជាបង្រៀនកុមារនេះ ត្រូវសាបញ្ជាក់អំពីមេលេខគុណ បង្រៀនសិស្សឲ្យចេះរកលេខគុណនឹងលេខចែក ចំនួនទាំងលេខបារាំងយុគ ហើយឲ្យចេះគិតគុណនឹងចែកចំនួនទាំង ១០ ទាំង ១០០ ។

មេរៀនទី ១ .— សាបង្រៀនអំពីមេលេខគុណ ជារបៀបបញ្ជាក់ឲ្យដឹងថាសិស្សចេះមេលេខគុណច្បាស់ហើយឬនៅ ។

របៀបបង្រៀន .— សួរសាកបញ្ជាក់អំពីមេលេខគុណដូចជា:

៧×៣=..... ។ ៥×៤=. ... ។ ៩×៥=..... ។ ៧×៦=... ។ល។

ដូចជា ៧ បីដងត្រូវជាប៉ុន្មាន ។ ៥ បួនដងត្រូវជាប៉ុន្មាន ។ល។

ពាក្យសួរបែបនេះឲ្យបានច្រើន ពីព្រោះមិនត្រូវឲ្យសិស្សសូត្រមេលេខ ត្រាន់តែចាំថា ២ មួយដង ២ ។ ២ ពីរដង ៤ ។ ៣ ពីរដង ៦ ។ល។ ដូច្នេះទេ គឺត្រូវឲ្យសិស្សដឹងថា: ៤ ពីរដងត្រូវជា ៨ ។ ៧ ពីរដងត្រូវជា ១៤ ។

ដើម្បីកុំឲ្យរបៀបបង្រៀននោះដែលនាំឲ្យសិស្សធុញទ្រាន់ សូមប្រែផ្លាស់ប្តូររបៀបពាក្យសួរឲ្យសិស្សឆ្លើយដោយមាត់ទទេ ដោយសរសេរនៅលើក្តារខៀន ឬដោយពាក្យសួរជាចំណោទលំហាត់ឲ្យសិស្សឆ្លើយដោយមាត់ទទេ ឬសរសេរនៅលើក្តារខៀនបាន ។

# ការហាត់សរសេរនៅក្នុងសៀវភៅ.–

១– ចូរគិតចំនួនខាងក្រោមនេះ៖

៤៍ × ៥ = .... ។ ៧៍ × ៩ = .... ។ ៨៍ × ៦ = .... ។ ៥៍ × ៧ = .... ។

ក្នុង ៤២៍ មាន ៦៍ ប៉ុន្មានដង ។ ក្នុង ៦៣៍ មាន ៧៍ ប៉ុន្មានដង ។ ក្នុង ៤៥៍ មាន ៩៍ ប៉ុន្មានដង ។ ក្នុង ៥៤៍ មាន ៩៍ ប៉ុន្មានដង ។

២– បំណោទ.– ខ្ញុំមានប្រាក់ ៣៧៍ ខ្ញុំទិញសៀវភៅ ៥ ថ្លៃ ៣៍ ក្នុងសៀវភៅមួយ ។ ខ្ញុំបានទិញសៀវភៅអស់ប្រាក់ .... រៀល ហើយខ្ញុំនៅសល់ប្រាក់ .... រៀលទៀត ។

## មេរៀនទី ២.– រៀនគុណចំនួននឹងលេខមួយតួ ។

## របៀបបង្រៀន.–

១– ការហាត់គិតមាត់ទទេ.

ដោយសួរសិស្សអំពីមេលេខគុណ.

២– ពន្យល់របៀបធ្វើលេខគុណ.

គ្រូដាក់ចំណោទមួយថា: អង្ករ ១ ហាបថ្លៃ ១៤៧៍ តើអង្ករ ៥ ហាបត្រូវជាថ្លៃប៉ុន្មាន ។ គ្រូធ្វើលេខគុណ ១៤៧៍ × ៥ = ... នេះនៅលើក្ដារខៀន ឲ្យសិស្សមើលហើយពន្យល់របៀបធ្វើលេខគុណនេះ ។

៣ – ការហាត់បញ្ជាក់នៅលើក្ដារខៀន:

៤៣៛ × ៥ = . . . . ។ ៧៣៛ × ៧ = . . . . ។ ១៤៧៛ × ៤ = . . . ។

៤ – ការហាត់បញ្ជាក់នៅលើក្ដារឆ្នួន:

៥៧៛ × ៣ = . . . . . ។ ៦៩៛ × ៥ = . . . . . ។ ២១៧៛ ២ = . . . . ។

៥ – ការហាត់សរសេរនៅក្នុងសៀវភៅ:

ក – ចូរធ្វើលេខខាងក្រោមនេះ

| | | | |
|---|---|---|---|
| ២៥៛ | ៧៩៛ | ១៤៧៛ | ១២៥៛ |
| × ៧ | × ៥ | × ៣ | × ៦ |

ខ – បំណោទ.– ឪពុកខ្ញុំគាត់មានប្រាក់ ៧៩៣ រៀល គាត់ចាយទិញស្បៃ ៧ ហាបថ្លៃ ៥៧៛ ក្នុងមួយហាប ។ តើគាត់ត្រូវនៅសល់ប្រាក់ប៉ុន្មានទៀត ។

## មេរៀនទី ៣.– រៀនចែកចំនួនដោយលេខមួយខ្ទង់ ។

របៀបបង្រៀន.– ធ្វើតាមរបៀបបង្រៀនធ្វើលេខគុណខាងលើនេះ

## ការហាត់សរសេរនៅក្នុងសៀវភៅ.–

១ – ចូរធ្វើលេខខាងក្រោមនេះ:

៤៧៦៛ | ៤      ១៧៥៛ | ៥      ៣៥០៛ | ៧

២- បំណោទ.— ឪពុកខ្ញុំគាត់ទិញស្រូវ ៦ ហាបថ្លៃ ៤៥០៛ ។ តើស្រូវ ១ ហាបថ្លៃប៉ុន្មាន ។ បើគេទិញស្រូវនោះ ៩ ហាប ត្រូវជាថ្លៃប៉ុន្មាន ។

រង្វាស់រង្វាល់.— ក្នុងខែនេះត្រូវបង្រៀនអំពីរូបិយវត្ថុ នឹងក្រដាសប្រាក់ដែលចាយនៅក្នុងសហឥណ្ឌូចិន ។

របៀបបង្រៀនបានតែងចុះសំរាប់ខែកុម្ភមុននេះស្រាបហើយ

## ផល្គុន

### កុមារដ្ឋាន

ចំនួនពី ៨០ ដល់ ១០០ រាប់មួយៗ ពី ១ ដល់ ៨០ លេខបូកនឹងលេខដកមានត្រាទុក ចែកចំនួនរបស់ជា ៤ ភាគស្មើគ្នា ។

### បំណោទ

មតិសំខ្យា.— ត្រូវឲ្យសិស្សរាប់ ពី ១ ដល់ ៨០- គឺបន្ថែមម្តង ២ - ម្តង ៣ - ម្តង ៤ - រួចបន្ថយម្តង ២ - ម្តង ៣ - ម្តង ៤ - ពី ៨០ មក ១ វិញ ។

មេរៀន.— រាប់មួយៗ ពី ១ ដល់ ៨០ ។ រៀនចំនួនពី ៨០ ដល់ ១០០

របៀបបង្រៀន.— បង្រៀនរាប់ - មើលចំនួន - សរសេរចំនួន ។

ការរៀបចំជាមុន.— ត្រូវមានរបស់ដូចជាបន្ទះដល់ចំនួន ១០០- សរសេរលេខពី ១ ដល់ ៨០ នៅលើក្ដារខៀន ។

## ក/-រាប់ម្ដងដប់ៗពី ១ ដល់ ៨០.— ឲ្យសិស្សរាប់បន្តើរ ១ ជាប់ៗ ឬ

មួយសេនបង្គោមៗ ។ ឲ្យរាប់ថា : ១០ -២០ - ៣០ - ៤០ - ៥០ - ៦០ - ៧០ - ៨០ ។ ឲ្យរាប់ថយមកវិញ = ៨០ - ៧០ - ៦០ - ៥០ - ៤០ - ៣០ - ២០ - ១០ ។

### ១/- រាប់ម្ដងមួយៗ ·— ប្រាប់សិស្សថាយើងមាន ៨០ ហើយ ។

ឥឡូវនេះយើងស្រាយជាប់ទី៩ និងទី ១០ ទៀត ហើយយើងបន្ថែម ១ ម្ដងៗ ទៅលើចំនួន ៨០ យើងថា : ៨០ និង ១ ត្រូវជា ៨១; ៨០ និង ២ ត្រូវជា ៨២; ៨០ និង ៣ ត្រូវជា ៨៣ ... រហូតដល់ ៩៩ និង ១ ត្រូវជាមួយរយ ។ ដំរូលេខនីមួយៗបានហើយ សូមសរសេរលេខនោះរៀងៗគ្នា គពី ៨០ និងដីសពណ៌ ) ។

យើងសរសេរលេខ

| | | |
|---|---|---|
| ១ | ០ | ០ |

យ៉ាងដូច្នេះ ។

សូមពន្យល់ខ្ទង់រយ- ខ្ទង់ដប់ និងខ្ទង់រាយ ។

សូមឲ្យសិស្សសរសេរលេខ ១០០ គ្រប់គ្នានៅលើក្ដារខៀន - រួចឲ្យរាប់បន្ថែមម្ដង ១ ម្ដង២ ម្ដង ៣ ម្ដង ៤ ពី១ ដល់ ១០០ ។ បន្ថយដូចគ្នា ពី ១០០ មក ១វិញ ។

### បង្រៀនមើលចំនួន .— *ឲ្យសិស្សមើលចំនួនពី ៨០ ដល់ ១០០ ឲ្យថាឲ្យច្បាស់ៗ ។*

### បង្រៀនសរសេរចំនួន.— *សូមឲ្យសិស្សសរសេរចំនួនតាមពាក្យគ្រូថាៗ*

### ការបាត់មាត់ទទេ .— ១)- មានលេខប៉ុន្មាននៅខ្ទង់ដប់ មានលេខប៉ុន្មាននៅ

ខ្ទង់រាយ ក្នុងចំនួន ប៉ែតសិបប្រាំ - កៅសិបប្រាំបី · ប៉ែតសិបពីរ - កៅសិប.....ល.... ។

២ )- ឲ្យរកហើយសរសេរចំនួនបួន - ប្រាំ ដែលមានលេខនៅខ្ទង់ដប់ច្រើនជាងខ្ទង់រាយ ។ ប្រាំ ប្រាំមួយដែលមានលេខរាយច្រើនជាងខ្ទង់ដប់ ។

### បំណោទឲ្យធ្វើ .— *ក្នុងមួយមានសៀវភៅ ៩៨ លោកគ្រូបែកឲ្យសិស្សម្ដង ៣៥ · ម្ដងទៀត ៤៦ ។ តើសៀវភៅនៅសល់ប៉ុន្មានទៀត ។*

# លេខបូកនិងលេខសងមាន
# ត្រាទុក

សូមបង្រៀនលេខបូក-សងឲ្យមានត្រាទុកគិតចំនួនពី ៨១ ដល់ ១០០ ឲ្យច្រើនដោយពោលសួរ ហើយដោយធ្វើនៅក្ដារខៀនបញ្ឈរ ។

ឧបមាដូចជា ៨០ រៀលនិង ២ រៀលនិង ៦ រៀលត្រូវជាប៉ុន្មានរៀល? ៩០ រៀលដក ៤ រៀល រួចដក ៣ រៀលទៀត តើនៅសល់ប៉ុន្មាន?

**វិធីហាត់សរសេរ..** ចូរធ្វើលេខខាងក្រោមនេះ :

| | | | |
|---|---|---|---|
| ៦៤ ក | ៥២ ខ | ៩០ គ | ១០០ ឃ |
| + ២៦ | + ៣៩ | − ៣៦ | − ២៣ |
| ក | ខ | គ | ឃ |

# ចែកចំនួនរបស់ជា ៤ ភាគ
# ស្មើគ្នា

ឧបមាដូចជា : ៣២ : ៤

១). អ្នកដាំដំណាំម្នាក់ចង់ដាំដើមសាឡាត់ ៣២ ដើម ជា ៤ ជួរ តើអ្នកនោះត្រូវដាំសាឡាត់ប៉ុន្មានដើមក្នុង ១ ជួរ?

តើ ៤ ប៉ុន្មានដង ទើបត្រូវជា ៣២? ក្នុងមេរៀនខ្ញុំដឹងថា ៤ ប្រាំបីដង ត្រូវជា ៣២ ។ ដូច្នោះ អ្នកដាំដំណាំនោះត្រូវដាំសាឡាត់ ៨ ដើមក្នុង ១ ជួរ ។

២)- ទាហាន ៣២ នាក់ឈរជាជួរ ក្នុង ១ ជួរមាន ៤ នាក់ ។ តើទាំងអស់មានប៉ុន្មានជួរ? - ក្នុង ៣២ មាន ៤ ប៉ុន្មានដង? ខ្ញុំដឹងថា: ៤ ប្រាំបីដងត្រូវជា ៣២ ។ ដូច្នោះខ្ញុំឃើញថា មានទាហានឈរ ៨ ជួរ ។

ឧទាហរណ៍នីមួយៗ ខាងលើនេះ ខ្ញុំចែក ៣២ នឹង ៤ ។ ខ្ញុំថា: ៣២ ចែកនឹង ៤ ត្រូវជា ៨ ។

ខ្ញុំសរសេរ ៣២ : ៤ = ៨ ។

៨ ជាផលហារនៃលេខ ៣២ ចែកនឹង ៤ ។

ការហាត់មាត់ទទេ.- ផ្លែឪឡឹក ១ ថ្លៃ ៤ រៀល តើខ្ញុំទិញបានឪឡឹកប៉ុន្មាន បើខ្ញុំមានប្រាក់ ២០ រៀល, ៣៦ រៀល, ១៦ រៀល, ២៤ រៀល, ២៨ រៀល, ។

បំណោទ.- ១)- បងប្អូន ៤ នាក់ចែកមតិកភ្ជា ក្របី ១៦, គោ ២៨ និងជ្រូក ៣២ ។ បងប្អូនម្នាក់ៗបានក្របី ....., គោ...... និងជ្រូក.....។

២)- ក្នុងទីចិញ្ចឹមសត្វមួយ មានមាន់ ៦ ហើយនឹងទន្សាយច្រើន ។ ជើងសត្វទាំងអស់នោះរួមទៅឃើញ ៦០ ។ តើជើងទន្សាយ មានប៉ុន្មាន? មានទន្សាយប៉ុន្មាន?

## រង្វាស់រង្វាល់

*ប្រាក់រៀល - ប្រាក់កាក់ - លុយសេន - បង្ហាត់ក្មេងឲ្យចេះដូរ - ទិញ ថែមថយលុយ ។*

ការរៀបចំជាមុន.- *សូមឲ្យរកប្រាក់រៀល - ប្រាក់កាក់ ១០ សេន ២០ សេន - ៥០ សេន - លុយសេន ១ សេន ។*

ការហាត់ពិនិត្យប្រាក់និងលុយ.- *សូមឲ្យសិស្ស ។*

*ក)- ពិនិត្យមើលជាតិប្រាក់ - ស្ពាន់ - ទង់ដែង ។*

*ខ)- ពិនិត្យមើលទំហំ - កំពស់ - ពណ៌ - និងអក្សរនៅលើប្រាក់រៀល កាក់ - លុយ នីមួយៗ ។*

**ការហាត់សំគាល់ស្ដាប់សូរសម្លេងប្រាក់នឹងលុយ.—** យកប្រាក់នឹងលុយមកទម្លាក់នៅលើតុ ឲ្យសិស្សប្រុងស្ដាប់ ហើយឲ្យដឹងថា នេះសូរប្រាក់រៀល - ប្រាក់ ៥ សេន ប្រាក់ ២០ សេន - ប្រាក់ ១០ សេន នឹងលុយ ១ សេន ។

រួចឲ្យសិស្សធ្មេចភ្នែកចាំថាឈ្មោះប្រាក់ដែលគ្រូទម្លាក់ទៅលើតុ ។

(សូមប្រាប់សិស្សថា ឥឡូវនេះគេពុំសូវចាយប្រាក់រៀលទេ ពីព្រោះប្រាក់រៀលនេះធ្ងន់យកទៅណាពីបាក ហើយយកមិនបានច្រើនផង ដូច្នេះបានជាគេធ្វើក្រដាសប្រាក់ចាយវិញ ឲ្យងាយយកជាប់នឹងខ្លួនទៅបានងាយ ។ គ្រូឲ្យសិស្សដឹងថា ប្រាក់ក្រដាសដែលយើងចាយសព្វថ្ងៃនេះ មានអំណាចចាយបាន តែនៅប្រទេសឥណ្ឌូចិន គឺក្នុងនគរខ្មែរ - នគរលាវ នឹងនគរយៀកណាម ។

**ការហាត់មាត់ទទេ.—** ឲ្យសិស្សគិត:- ប្រាក់កាក់ ១០ សេន ៣

ប្រាក់កាក់ ២០ សេន ១

លុយសេន ៦

ទាំងអស់ត្រូវជា ......... សេន ។

ខ្ញុំមានប្រាក់កាក់ ៥០ សេន ២ ។ ទៅទិញទឹកកកអស់ ១០ សេន ទិញអន្សម បក ២០ សេន ។ តើខ្ញុំនៅសល់ប៉ុន្មានសេនទៀត ។

**បំណោទ.—** ១)- អ្នកមានលុយ ៥០ សេន ។ ម្ដាយអ្នកឲ្យ ៥០ សេនទៀត - ឪពុកអ្នកឲ្យ ២៥ សេនទៀត ។ រួចអ្នកទិញខ្មៅដៃ ១ ថ្លៃ ៩០ សេន ។ តើអ្នកនៅសល់ប៉ុន្មានមកផ្ទះវិញ ។

២)- ខ្ញុំទិញសៀវភៅសរសេរមួយថ្លៃ ២៛.៤៥ - ទិញក្រដាសជូត ១ សន្លឹកថ្លៃ ០៛.៥០ ។ ខ្ញុំនៅសល់ ១៛.៨០ ទៀត ។ តើខ្ញុំមានប្រាក់ប៉ុន្មានទៅផ្សារ?

អាទិតដ្ឋាន

## វត្ថុស្វាធ្យាយន៍

## អាទិត្យទី ១ – អំពីអាកាស

សុំឲ្យគ្រូរកដបមួយ ទឹកមួយចានក្លាំងកែវទឹកឬកូនដបមួយមកបញ្ជាក់បង្រៀន ។

របៀបបង្ហាញ.– ឲ្យសិស្សយកដបឬសៀវភៅសសេរបក់ចុងវា មានអ្វីមកប៉ះមុខឯង ។ កាលណាឯងផ្លុំប៉េង ហេតុដូចម្ដេចបានជាកាវឯងប៉ោងធំឡើង ។ ឲ្យយកកែវទឹកទទេផ្កាប់ហើយជ្រមុជទៅក្នុងទឹកចាន ទឹកចូលពេញកែវឬទេ? ។ ហេតុអ្វី? ផ្អៀងកែវបន្តិច ឃើញហេតុយ៉ាងណា? ។ មានពពុះផុសចេញពីកែវហើយឡើងមកលើ នៅលើទឹកពពុះនោះគឺអ្វី? ។ បើដូច្នេះអាកាសនៅកន្លែងណាខ្លះ ។ គ្រប់កន្លែងសូម្បីតែប្រហោងតូចក៏មានអាកាសដែរ ។ កាលណាយើងដកដង្ហើម យើងស្គាល់ខ្យល់អាកាសដែលចេញចូលបានឬទេ? យើងមើលឃើញអាកាសឬទេ? ។ បើដូច្នេះអាកាសគ្មានពណ៌គ្មានក្លិន ។

ប្រយោជន៍នៃអាកាស.– មនុស្សលង់ទឹកបន្តិច ហេតុអ្វីបានជាស្លាប់ បើយកថង់មួយគ្របច្រមុះកុំឲ្យអាកាសចូលបាន មនុស្សនឹងស្លាប់ បើដូច្នេះមនុស្សសត្វទាំងពួងត្រូវការនឹងអាកាស ។ ដុតទៀនមួយឲ្យឆេះហើយយកចានមួយគ្របឲ្យជិត ឯងឃើញហេតុយ៉ាងណាទៀតលេក ។ ពីព្រោះអ្វី ?

គ្មានអាកាសទឹងនេះ ។ ដូច្នេះតែគ្មានអាកាសតែផ្សេង ៗ មិនអាចទឹងនេះបានឡើយ ។

មេរៀនសង្ខេប- អាកាសមាននៅគ្រប់កន្លែង គ្រប់ជម្រៅ អាកាសអាចទឹងជួយទ្រទ្រង់ជាតិមនុស្សសត្វទឹកក្រៅភពផែនដីទាំងឡាយ ៗ តែគ្មានអាកាសកើតពុំអាចទឹងនេះបានឡើយ ។

## អាទិត្យទី ២.— អំពីពពក

សុំគ្រែកឆ្នាំងតូចមួយ កូនចង្ក្រានមួយ និងចានទាបមួយមកធ្វើឲ្យសិស្សពិនិត្យមើលហើយនិងគេឲ្យឃើញហេតុ ។

ការធ្វើឲ្យមើល .— តាក់ទឹកទៅក្នុងឆ្នាំងហើយដាំឲ្យពុះ លុះទឹកពុះបើកគ្របឡើង ៗ អ្វីដែលហុយចេញពីឆ្នាំងឡើង ៗ ចំហាយទឹកហុយឡើង ចំនួនទឹកក្នុងឆ្នាំងក៏ថយ យកចានទាបដាក់លើមាត់ឆ្នាំង ចំហាយទឹកហុយទៅប៉ះហើយកកទៅជាដំណក់ទឹក ។

រំលឹកសតិបញ្ញាសិស្ស .— វេលាដែលក្ដៅទឹកទន្លេ បឹង សមុទ្រ ហួតឬទេ ។ ចំហាយទឹកដែលហួតបង្កជាអ្វី ។ ហេតុដូចម្ដេចបានជាកកទៅជាភ្លៀងបាន ។ កាលណាពពកអណ្ដែតទៅប៉ះនឹងអាកាសត្រជាក់ចំហាយទឹកនៅក្នុងពពកក៏កកទៅជាគ្រាប់ទឹកភ្លៀងធ្លាក់មកលើដី ។ ដល់ភ្លៀងរួចទឹកភ្លៀងនោះហូរជ្រាបទៅក្នុងដី ។ មួយភាគទៀតហូរតាក់ទៅក្នុងទន្លេធ្លាក់ទៅក្នុងសមុទ្រវិញដដែល ។

លក្ខណពពក.— ពពកខ្លះពណ៌ស ខ្លះជាផ្ទាំងខ្មៅ ជួនកាលមានជារូបកងចម្លែកហើយមានពណ៌ផ្សេង ៗ តាមព្រះអាទិត្យ ពពកដែលបង្គុំជាភ្លៀងធ្លាក់មកនោះ គឺជាពពកខ្មៅភាយទ័នជី ។

មេរៀនសង្ខេប .— ដោយចំហាយព្រះអាទិត្យ ទឹកនឹងហួតហើយកើតទៅជាចំហាយទឹកអណ្តែតផ្តុំគ្នាបានជាពពករសាត់តាមខ្យល់ ៗ ពពកមានផ្នែក ៗ ពីគ្នាតាមកំពស់តាមពេលវេលា ។ កាលណាអណ្តែតទៅប៉ះលើអាកាសត្រជាក់ពពកក៏កកទៅជាទឹកភ្លៀងធ្លាក់ចុះមក ។

## អាទិត្យទី ៣ .— ពំអីពេលវេលា

សុំឲ្យគ្រូកែកស្ទង់ធាតុ (ទែរម៉ូម៉ែត្រ) និងប្រដាប់ស្ទង់អាកាស (បារូម៉ែត្រ) មកបង្រៀនសិស្សឲ្យចេះមើលផង ។

## អាទិត្យទី ៤.- សារៀនរំឭកចំនួនប៉ុន្មានដែលបានបង្រៀនមកពីដើមខែ ។

# វិធីបង្ការរោគ

## អាទិត្យទី ១ .— អំពីជម្ងឺអាសន្នរោគ

ជម្ងឺអាសន្នរោគបង្កើតឡើងដោយហស់ ឲ្យកើតភ័យជាខ្លាំង រូបបណ្តាលឲ្យចុះផង ក្អួតផង ជាប់ ៗ គ្នាជាដើម ។ ជម្ងឺនេះធ្ងន់ណាស់ ហើយធ្វើឲ្យអ្នកស្រុកវិនាស ហេតុនេះត្រូវប្រយ័ត្នឲ្យមាំមួន ។

ឲ្យសិស្សរៀបរាប់អំពីជម្ងឺអាសន្នរោគដែលបានឮឬបានឃើញ

ពាក្យសួរ .— ជម្ងឺអាសន្នរោគមានកើតនៅរដូវណាខ្លះ ។ គេសំគាល់ដឹងជម្ងឺអាសន្នរោគបានដោយហេតុយ៉ាងណា ។ វានាំឲ្យអន្តរាយមនុស្សយ៉ាងដូចម្ដេច ។ គេត្រូវប្រយ័ត្នដូចម្ដេចខ្លះ ។ បានថ្នាំអ្វីមកបំបាត់រោគនោះបើកាលណាអ្នកនោះឆ្ងាយពីមន្ទីរសុខាភិបាល ។

មេរៀនសង្ខេប .— កាលណាមានឈឺជម្ងឺធ្ងន់ក្នុងផ្ទះ ត្រូវឲ្យមានសេចក្ដីប្រយ័ត្នដូចមានខាងក្រោមនេះ ចំពោះអ្នកជម្ងឺឲ្យនៅដោយខ្លួន អ្នកដែលថែជម្ងឺត្រូវមានសម្លៀកបំពាក់មួយ សំរាប់ចូលទៅក្នុងបន្ទប់ជម្ងឺ ត្រូវលាងដៃនឹងសាប៊ូរឺទឹកស្រា កាលណារួចការហើយ ។

អាទិត្យទី ២ .— កិច្ចត្រូវប្រព្រឹត្តវេលាដែលមានជម្ងឺឆ្លង (តមក) ការប្រយ័ត្នខាងចំណីអាហារ កុំឲ្យសិស្សបរិភោគផ្លែឈើខ្ចី ដូចជាស្វាយឬត្របែកជាដើម បន្លែស្រស់ឬផ្លែឈើណាដែលស្អុយរលួយ ទោះបន្តិចបន្តួចក៏ដោយ ។

នៅផ្ទះសំរែងចំណីអាហារត្រូវគ្របឲ្យជិត កុំឲ្យរុយរោមអាហារទៀត ត្រូវឲ្យធ្វើថ្មីៗ ហើយចំអិនប្រាកដ ទឹកទុកឲ្យយូរនៅលើភ្លើងសិមបរិភោគ ។

គេសង្ស័យដូចជាទឹកនេះក៏ដែរ បើប្រើទឹកទន្លេឬទឹកអណ្ដូងត្រូវយកមកដាំឲ្យពុះចំនួន ២០ មីនុតសិន ការប្រើទឹកកែកក៏ជាកិច្ច ១ យ៉ាងល្អដែរ ក៏ប៉ុន្តែត្រូវឲ្យទឹកពុះឲ្យយូរ ហើយមិនត្រូវចាក់ទឹកត្រជាក់លាយវេលារៀបនឹងផឹក ។

ការប្រយ័ត្នជាធំ បើកាលណាមានជម្ងឺឆ្លងក្នុងស្រុកក្នុងភូមិ ហើយត្រូវតែចូលទៅឲ្យគ្រូពេទ្យចាក់ថ្នាំ ការពារខ្លួនមុនជាកប ។

## មេរៀនសង្ខេប — សុំគ្រូតែងដាក់ឲ្យសិស្សរៀនផងចុះ

**អាទិត្យទី ៣ .—** កិច្ចដែលត្រូវប្រព្រឹត្តវេលាដែលមានជម្ងឺឆ្លង (តមក) ការរំងាប់នឹងជៀសវាងមេរោគ វេលាដែលអ្នកជម្ងឺមិនទាន់ជា ត្រូវឲ្យសំអាតទីលំនៅតុទូតាំង មិនត្រូវឲ្យមានសំរាមស្អុយរលួយនៅជិតផ្ទះសំបែង កុំប្រើប្រាស់របស់អ្នកជម្ងឺ ឯអ្នកជម្ងឺជាហើយទីកន្លែងអ្នកជម្ងឺ ត្រូវសំអាតរំងាប់មេរោគនឹងទឹកក្រេសីលបើកទ្វារបង្អួចឲ្យស្រឡះឲ្យពន្លឺនឹងអាកាសចូលឲ្យបានច្រើន សំលៀកបំពាក់អ្នកនោះ ត្រូវយកទៅស្ងោរលាងចេញប្រដាប់ប្រដាដែលអ្នកចាប់កាន់ប៉ះពាល់ក៏ត្រូវធ្វើដូច្នេះដែរ

## មេរៀនសង្ខេប — សុំគ្រូតែងផងចុះ

**អាទិត្យទី ៤.—** សារៀនវិជ្ជាទាំងប៉ុន្មានដែលបានបង្រៀនមកពីដើមរៀ ។

បរិច្ឆណាដ្ឋាន

## វត្ថុស្វាធ្យាយន៍

**អាទិត្យទី ១—** អំពីឆ្មា

សូមគ្រូឲ្យសិស្សចាប់ឆ្មាមួយយកមកបង្រៀន នាំសិស្សឲ្យពិនិត្យមើលគ្រប់ផ្នែកសត្វឆ្មា ។ ក្បាលឆ្មាពន់ដូចម្តេច ។ ឲ្យសិស្សសង្កេតមើលភ្នែក ។ យ៉ាំងដូចម្តេច ។ មានអ្វីជាចំឡែកពីភ្នែកសត្វឯទៀត ។ សត្វអ្វីទៀតដែលមានភ្នែកដូចឆ្មា ។ នៅមាត់មានដុះអ្វី ។ ឯពុកមាត់នេះប្រើការដូចម្តេច ។

សុំឲ្យបើកមាត់ឆ្មាមើលធ្មេញ សណ្ឋានដូចម្តេច ។ ធ្មេញណាធំជាងគេ ។ ហេតុដូចម្តេចបានជាចង្កូមនេះធំជាងធ្មេញឯទៀត ។ ព្រោះឆ្មាបរិភោគ

សាច់ បន្ថែមដុះធំឡើងដើម្បីនឹងទំពាសាច់ ធ្មេញសត្វណាដែលស៊ីសាច់ក៏ដូច្នេះ ដែរ ដូចជាឆ្កែ-ខ្លា-តោ ។

ឲ្យសិស្សមើលខ្លួនឆ្មា ភេទឆ្មាសណ្ឋានយ៉ាងណា ។ ពាល់ទៅដូចម្ដេច ។

ឲ្យសិស្សសង្កេតមើលជើងឆ្មា ឆ្មាមានជើងប៉ុន្មាន ។ សត្វដែលមាន ជើងបួនហៅសត្វអ្វី ។ នៅចុងជើងមានអ្វី ។ ក្រចកឆ្មាយ៉ាងដូចម្ដេច ។ កោង ខុបចុះក្រោមស្រួចលិចចូលលូតចេញបានតាមចិត្ត ។ ឯក្រចកនេះសម្រាប់ធ្វើ អ្វី ។ ចាប់ក្រញាំសត្វជាអាហារ ។ ហេតុដូចម្ដេចបានជាឆ្មាលាក់ក្រចក កាលណាវាដើរ ។ កុំឲ្យសឹក ។

កាលណាវាបញ្ចេញក្រចក ។

ឲ្យឆ្មាដើរ-លោត-ដំណើរឆ្មាយ៉ាងដូចម្ដេច ។ ដើរលបៗ ដំណើរទន់ ។ ប៉ុន្តែឆ្មាខ្លាំងហើយរហ័សណាស់ កាលណាវាចាប់សត្វបរិភោគ ឬមួយតយុទ្ធ នឹងសត្រូវ ។

សុំឲ្យគ្រូនិយាយអំពីពុកឆ្មាបន្តិចផង

**សេចក្ដីសង្ខេប**.— ឆ្មាជាសត្វជើងបួន (ចតុប្បាទ) ខ្លួនវែងមាន ស្បែកគ្របជិត ហើយមានរោមទន់ ។ ក្បាលវាមូល មានពុកមាត់វែង ។ ជើងវាមានម្រាមប្រាំ ខាងចុងមានក្រចកវែងស្រួច ។ វាលាក្រញាំក្រចក កាលណាវាចាប់កណ្ដុរយកមកគេះសម្លាប់ ។ ឆ្មាលោតបានឆ្ងាយហើយប្រសប់ ឡើងណាស់ ។ ធ្មេញវាតូចៗស្រួចហើយមុតណាស់ ឆ្មាស៊ីសាច់ដែរ ។

អាទិត្យទី ២— សំពត់ក្រី

អាទិត្យទី ៣— សំពត់កន្ទប

អាទិត្យទី ៤— សំពត់មេអំបៅ-ខ្នង-ជាខ្ទង

បរិច្ឆណាដ្ឋាន

## វិធីបង្ការរោគ

**អាទិត្យទី ១— កិច្ចដែលត្រូវប្រព្រឹត្តវេលាដែលមានជម្ងឺឆ្លង**

កាលណាមានជម្ងឺឈឺឆ្លងក្នុងផ្ទះ ត្រូវឲ្យមានសេចក្ដីប្រយ័ត្នដូចមានខាងក្រោមនេះ បំបែកអ្នកជម្ងឺឲ្យនៅដោយឡែក អ្នកដែលថែជម្ងឺត្រូវមានសំលៀកបំពាក់មួយប្រដាប់ផ្សេងមួយសំរាប់ចូលទៅក្នុងបន្ទប់ជម្ងឺ ត្រូវលាងដៃនឹងសាប៊ូរួចនឹងស្រាកាលណារួចការហើយ ។

**អាទិត្យទី ២ — ការរំងាប់និងជៀសវាងមេរោគ**

វេលាដែលអ្នកជម្ងឺមិនទាន់ជា ត្រូវឲ្យសំអាតទីលំនៅតុទូតាំង មិនត្រូវឲ្យមានសំរាមស្អុយរលួយនៅជិតផ្ទះសំបែង កុំប្រើប្រាស់របស់អ្នកជម្ងឺ លុះដល់អ្នកជម្ងឺជាហើយ ចំណែកខ្លួនអ្នកជម្ងឺត្រូវសំអាតរំងាប់មេរោគនឹងទឹកក្រេសូល បើកទ្វារបង្អួចឲ្យស្រឡះឲ្យពន្លឺនឹងអាកាសចូលឲ្យបានច្រើន សំលៀកបំពាក់អ្នកនោះ ត្រូវយកទៅស្ងោរលាងចេញ ប្រដាប់ប្រដាដែលអ្នកបានកាន់ប៉ះពាល់ក៏ត្រូវធ្វើដូចនេះដែរ ។

## អាទិត្យទី ៣– ការប្រយ័ត្នខាងចំណីអាហារ សុំគ្រូហាមប្រាមសិស្សកុំឲ្យបរិ-

ភោគផ្លែឈើខ្ចីជូរជាស្វាយខ្ចីជាដើម បន្លែស្រស់ឬបន្លែផ្លែឈើណាដែលស្អុយ រលួយពោះបន្តិចបន្តួចក៏ដោយ ។

នៅផ្ទះសំបែងចំណីអាហារត្រូវគ្របឲ្យជិត កុំឲ្យរុយពាមអាហារទៀត ត្រូវឲ្យឆ្អិនៗ ហើយចំអិនប្រាកដ គឺទុកឲ្យយូរនៅលើភ្លើងសមបរិភោគ ។

ភេសជ្ជៈដូចជាទឹកនេះក៏ដែរ បើប្រើទឹកទន្លេទឹកអណ្ដូងត្រូវយកមកដាំឲ្យពុះចំនួន ២០ មីនុតសិន បើប្រើទឹកតែក៏ជាកិច្ចមួយយ៉ាងល្អដែរ ក៏ប៉ុន្តែត្រូវឲ្យទឹកពុះឲ្យយូរ ហើយមិនត្រូវចាក់ទឹកត្រជាក់លាយ វេលារៀបទឹកផឹក

ការប្រយ័ត្នជាធំ បើកាលណាមានជម្ងឺឆ្លងក្នុងស្រុកក្នុងភូមិ ហើយត្រូវតែចូលទៅឲ្យគ្រូពេទ្យចាក់ថ្នាំ ការពារខ្លួនមុនជាកប ។

IMPRIMERIE
A. PORTAIL
PHNOM-PENH
TIRAGE 2. 706 EX